# ការស្តាប់សម្លេងស្ត្រីជាមួយមនុស្សជំនាន់ក្រោយ

# ស្តីពី

# អំពើហិង្សាយេនឌ័រក្នុងអំឡុងរបបខ្មែរក្រហម២០១៣




របាយការណ៍ស្តីពីដំណើរការនៃការស្តាប់សំឡេងស្ត្រីជាមួយមនុស្សជំនាន់ក្រោយ

និពន្ធដោយ  ប៉ៃនី យី  (Beini Ye)
កែសម្រួលដោយ ដួង សាវ៉ន (Duong Savorn)
រាជធានីភ្នំពេញ, ខែ មីនា  ឆ្នាំ ២០១៤
ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា
©Cambodian Defenders Project (CDP)

# មាតិកា




សេចក្តីផ្តើម ........ 1

- អ្នកផ្តល់សក្ខីកម្ម ........ 8
- មុំ វន់ ........ 12
- យាំ ឡាស់ ........ 16
- ឡោះ វណ្ណា ........ 19
- ជា ណុំ ........ 22

សំឡេងពីអ្នកចូលរួម ........ 25

- ការរកឃើញ ........ 29
- ការផ្តល់អនុសាសន៍ ........ 31

# សេចក្តីផ្តើម




របាយការណ៍នេះរៀបរាប់សង្ខេបអំពីដំណើរការ និងលទ្ធផលនៃការស្តាប់សំឡេងស្ត្រីជាមួយមនុស្សជំនាន់ក្រោយ ដែលបានរៀបចំឡើងនាថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ រាជធានីភ្នំពេញ ប្រទេសកម្ពុជា។ ការស្តាប់សំឡេងស្ត្រីជាមួយមនុស្សជំនាន់ក្រោយ ត្រូវបានរៀបចំដោយក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (CDP) ដោយមានការសហការជាមួយអង្គការចិត្តសង្គមអន្តរវប្បធម៌ (TPO) និងអង្គភាពគាំពារជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ. ត.ក)។

ការស្តាប់សំឡេងស្ត្រីជាមួយមនុស្សជំនាន់ក្រោយ គឺជាយន្តការយុត្តិធម៌អន្តរកាលក្រៅប្រព័ន្ធតុលាការសម្រាប់អ្នកនៅរស់រានមានជីវិតពីរបបខ្មែរក្រហម។ អ្នកនៅរស់រានមានជីវិតទាំងនេះ ផ្តល់ជាវេទិការមួយដែលនិយាយរៀបរាប់អំពីរឿងរ៉ាវពិតនៃអំពើហិង្សាផ្លូវភេទ និង យេនឌ័រ ដែលបានកើតមានក្នុងអំឡុងរបបនោះ។ ការស្តាប់សំឡេងស្ត្រីជាមួយមនុស្សជំនាន់ក្រោយឆ្នាំ ២០១៣ មានគោលដៅជាក់លាក់ ក្នុងការបង្កើតកិច្ចសន្ទនារវាងអ្នកនៅរស់រានមានជីវិតពីរបបខ្មែរក្រហម និងយុវជន ដើម្បីលើកកម្ពស់ការយល់ដឹងអំពីអំពើហិង្សាផ្លូវភេទ និងយេនឌ័រ និងដើម្បីបង្កើតឱ្យមានការពិភាក្សាអំពីការឆ្លើយតបទៅនឹងបទឧក្រិដ្ឋកើតមានពេលកន្លងមក និងការការពារអំពើហិង្សាលើស្ត្រីនាពេលអនាគត។

នៅក្នុងកម្មវិធីនៃការស្តាប់សំឡេងស្ត្រីជាមួយមនុស្សជំនាន់ក្រោយ មានស្ត្រីនៅរស់រានមានជីវិតពីរបបខ្មែរក្រហមចំនួនបួននាក់ បានអញ្ជើញមកចែករំលែកបទពិសោធន៍របស់ខ្លួនអំពីអំពើហិង្សាផ្លូវភេទ និងយេនឌ័រ នៅចំពោះមុខគណៈវិនិច្ឆ័យក្រុមនិស្សិតកម្ពុជា និងអ្នកចូលរួមជាង៤០០នាក់។ អ្នកដែលបានអញ្ជើញចូលរួមមានដូចជា និស្សិតមកពីតាមមហាវិទ្យាល័យក្នុងស្រុក ប៉ុន្តែក៏មានដើមបណ្តឹងរដ្ឋប្បវេណី តំណាងមកពីអង្គការជាតិ និងអន្តរជាតិ រួមទាំងមន្ត្រីសាលាក្តីខ្មែរក្រហម (អ.វ.ត.ក) ផងដែរ។ និស្សិតមហាវិទ្យាល័យចំនួនប្រាំមួយនាក់បានជ្រើសរើសធ្វើជាក្រុមគណៈវិនិច្ឆ័យ ដោយមានការគាំទ្រពីក្រុមការងារ និស្សិតពិសេសបន្ថែមចំនួនដប់នាក់ទៀត។ បន្ទាប់ពីការផ្តល់សក្ខីកម្មរបស់អ្នកនៅរស់រានមានជីវិត ក្រុមគណៈវិនិច្ឆ័យជានិស្សិតបានធ្វើការប្រកាសជាសាធារណៈ នូវសេចក្តីថ្លែង

ការណ៍ជាមួយលទ្ធផលរកឃើញស្ដីពីបញ្ហានៃអំពើហិង្សាផ្លូវភេទ និងយេនឌ័រ ក្នុងអំឡុងរបបខ្មែរក្រហម និងផ្ដល់ជាអនុសាសន៍ដល់ភាគីពាក់ព័ន្ធជាច្រើនទៀត។

ការស្ដាប់សំឡេងស្ត្រីជាមួយមនុស្សជំនាន់ក្រោយ បង្កើតបានជាផ្នែកនៃគម្រោងរួមស្ដីពីស្ត្រី និងយុត្តិធម៌អន្តរកាលក្នុងប្រទេសកម្ពុជាដែលកំពុងត្រូវបានអនុវត្តដោយអង្គភាពគាំពារជនរងគ្រោះ អង្គការចិត្តសង្គមអន្តរវប្បធម៌ និងក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ចាប់តាំងពីឆ្នាំ២០១១ ដោយមានការគាំទ្រផ្នែកហិរញ្ញវត្ថុពីមូលនិធិរបស់អង្គការសហប្រជាជាតិ ដើម្បីបញ្ចប់អំពើហិង្សាលើស្ត្រី។



# ប្រវត្តិសង្ខេប និងបរិបទ

ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ បក្សកុម្មុយនីស្តកម្ពុជាត្រូវបានស្គាល់ជាទូទៅថា របបខ្មែរក្រហម ដែលគ្រប់គ្រងប្រទេសកម្ពុជា និងត្រូវបានប្តូរឈ្មោះជាថ្មីថា "កម្ពុជាប្រជាធិបតេយ្យ"។ នៅក្រោមការដឹកនាំរបស់ ប៉ុល ពត, នួន ជា, អៀង សារី និងសមាជិកដទៃទៀតនៃបក្សកុម្មុយនីស្តកម្ពុជា ប្រទេសកម្ពុជាទាំងមូលត្រូវបានផ្លាស់ប្តូរទៅជាគុក ជំរុំការងារដ៏ធំល្វឹងល្វើយ អមដោយមន្ទីរឃុំឃាំងជាច្រើនទៀតដើម្បីឈានទៅសម្រេចបាន "បដិវត្តន៍សង្គមនិយម" របស់បក្សកុម្មុយនីស្តកម្ពុជា។ ប្រជាជនត្រូវបានបង្ខំឱ្យធ្វើការយ៉ាងធ្ងន់ធ្ងរដោយអមនុស្សធម៌។ ទង្វើនេះបានបណ្តាលឱ្យមនុស្សជាច្រើនពាន់នាក់ស្លាប់បាត់បង់ជីវិត ដោយសារភាពអត់ឃ្លាន ជំងឺ និងស្ថានភាពរស់នៅក្នុងភាពអាក្រក់ តឹងតែង។ ស្របពេលជាមួយគ្នានេះ បក្សកុម្មុយនីស្តកម្ពុជាបានព្យាយាមយ៉ាងឥតស្រាកស្រាន្តក្នុងការលុបបំបាត់កម្មសិទ្ធិឯកជន ដែលពួកគេយល់ឃើញថាជាសត្រូវនៃរបបរបស់ខ្លួន។ ក្រោមការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជារយៈពេលជិតបួនឆ្នាំ ការឃុំខ្លួន ការធ្វើទារុណកម្ម និងការសម្លាប់រង្គាលលើប្រជាជនស្លូតត្រង់បានកើតឡើងជាទូទៅនៅគ្រប់ទីកន្លែង។ តាមការប៉ាន់ស្មាន មនុស្សចំនួនជិតពីរលាននាក់បានបាត់បង់ជីវិតក្នុងរបបនេះ។



*រូបឆ្លាក់លើផ្ទាំងថ្មក្នុងខេត្តបាត់ដំបង ដែលបង្ហាញពីការរំលោភជាក្រុមពីកម្មាភិបាលខ្មែរក្រហម។*

មានករណីជាច្រើនទៀតកើតឡើងដោយគេមិនបានដឹង ក្រៅពីទម្រង់ផ្សេងៗនៃអំពើហិង្សាផ្លូវភេទ និងយេនឌ័រលើស្ត្រី[1] រួមទាំងការសម្លាប់ និងការរំលោភបំពាន។ ការសិក្សាស្រាវជ្រាវដែលបានអនុវត្តដោយក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជាក្នុងឆ្នាំ២០០៨ និង២០១១ បានវាយតម្លៃលើលក្ខណៈនៃអំពើហិង្សានេះ និងបានសន្និដ្ឋានថា ឧក្រិដ្ឋកម្មហិង្សាផ្លូវភេទនិងយេនឌ័រ បានកើតឡើងជាច្រើនក្នុងរបបនេះ។ ឧក្រិដ្ឋកម្មទាំងនេះ រួមមាន ការរំលោភសេពសន្ថវៈ ការរំលោភជាក្រុមពីជនល្មើសជាច្រើននាក់ ការរំលោភទ្រង់ទ្រាយធំលើជនរងគ្រោះច្រើននាក់ ការរំលោភដោយប្រើឧបករណ៍ផ្សេងៗ ការបង្ខំឱ្យអាក្រាតកាយ ការធ្វើអាជីវកម្មផ្លូវភេទ និងការបង្ខំឲ្យរៀបការ។

ដោយសារមិនមានការសិក្សាបែបបរិមាណលើចំនួនប្រជាជន ទំហំភូមិសាស្ត្រជាក់ស្តែង ចំនួនជនរងគ្រោះ ជនល្មើស និងចំនួនករណីបទឧក្រិដ្ឋអំពើហិង្សាផ្លូវភេទនិងយេនឌ័រ នៅតែមិនទាន់ដឹងច្បាស់នៅឡើយ។ ការមិនមានទិន្នន័យអំពីបញ្ហាទាំងនេះធ្វើឱ្យមានការយល់ឃើញថា ក្នុងរបបខ្មែរក្រហមមិនមានអំពើហិង្សាផ្លូវភេទនិងយេនឌ័រលើស្ត្រីឡើយ។ លើសពីនេះ ការយល់ឃើញនេះអាចរកឃើញក្នុងក្រម សីលធម៌របស់បក្សកុម្មុយនីស្តកម្ពុជាសម្រាប់កម្មាភិបាល ដែលបានចែងអំពីបទឧក្រិដ្ឋដែលអាចដាក់ទណ្ឌកម្មបានចំពោះ "ការប្រព្រឹត្តខុសសីលធម៌"។ ការសិក្សាស្រាវជ្រាវរបស់ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជាបង្ហាញថា ជាការពិតបទល្មើសផ្លូវភេទដែលប្រព្រឹត្តដោយកម្មាភិបាល កម្រត្រូវបានគេធ្វើការស៊ើបអង្កេតណាស់។ ជនរងគ្រោះមិនទទួលបានសំណង ចំណែកជនល្មើសក៏មិនត្រូវបានដាក់ទណ្ឌកម្មដែរ។ គួបផ្សំជាមួយការរើសអើង និងការមាក់ងាយក្នុងសង្គមដែលជនរងគ្រោះជួបប្រទះ ការយល់ឃើញបែបនេះកាន់តែបង្កើនឱ្យមានជំនឿខ្លាំងឡើងថា មិនមានករណីអំពើហិង្សាផ្លូវភេទ និងយេនឌ័រក្នុងរបបនេះឡើយ និងរារាំងដល់ស្ត្រីជាច្រើនក្នុងការស្វែងរកការគាំទ្រ និងលទ្ធភាពទទួលបានយុត្តិធម៌។

នាពេលកន្លងមក មានកិច្ចប្រឹងប្រែងជាច្រើនបានបង្កើតឡើងក្នុងប្រទេសកម្ពុជា ដើម្បីដោះស្រាយរឿងរ៉ាវដែលជាកេរដំណែលនៃបក្សកុម្មុយនីស្តកម្ពុជា តាមរយៈការពង្រឹងដំណើរការយុត្តិធម៌អន្តរកាល។ យន្តការសំខាន់បំផុតគឺ អ.វ.ត.ក ដែលជាតុលាការឧក្រិដ្ឋកម្មសង្គ្រាមអន្តរជាតិកូនកាត់ មានមុខងារ

[1] Nakagawa *អំពើហិង្សាយេនឌ័រក្នុងរបបខ្មែរក្រហម – រឿងរ៉ាវរបស់អ្នកនៅរស់រានមានជីវិតពីកម្ពុជាប្រជាធិបតេយ្យ*២០០៨។ Natale *ខ្ញុំភ័យស្ទើរលស់ប្រលឹងអស់ពីខ្លួន – ការសិក្សាស្រាវជ្រាវមួយស្តីពីអំពើហិង្សាយេនឌ័រក្នុងកម្ពុជាប្រជាធិបតេយ្យក្នុងខេត្តបាត់ដំបង និងស្វាយរៀង* ឆ្នាំ២០១១។ អត្ថបទទាំងពីរអាចរកបានក្នុងគេហទំព័រ www.gbvkr.org/publications and material/research and documentation ។

ប្តឹងចោទប្រកាន់លើមេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា។ អ.វ.ត.ក គឺជាតុលាការតែមួយគត់ ដែលជំនុំជម្រះរឿងក្តីឧក្រិដ្ឋកម្មកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ នៅតុលាការនេះជនរងគ្រោះ អាចចូលរួមជាភាគីដើមបណ្តឹងរដ្ឋប្បវេណីដោយទទួលបានសិទ្ធិផ្នែកនីតិវិធី និងសិទ្ធិក្នុងការទាមទារ សំណងសម្ហូភាព និងសំណងផ្លូវចិត្ត។ អ្នកនៅរស់រានមានជីវិតជាច្រើនដែលទទួលរងអំពើហិង្សាផ្លូវ ភេទនិងយេនឌ័រ គឺស្ថិតក្នុងចំណោមភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលស្គាល់ក្នុង ដំណាក់ កាលនៃការជំនុំជម្រះរបស់តុលាការ។ តុលាការនេះបានចាត់ទុកថា "ការបង្ខំឲ្យរៀបការ" គឺជាបទឧក្រិដ្ឋ ប្រឆាំងនឹងមនុស្សជាតិ ដែលជាករណីមួយក្នុងចំណោមករណីនានា ប៉ុន្តែបទឧក្រិដ្ឋនេះមិនត្រូវបាន ដាក់បញ្ចូលក្នុងដំណើរការរបស់តុលាការឡើយ។

ស្របជៀងគ្នានឹង អ.វ.ត.ក អង្គការសង្គមស៊ីវិលបានផ្តួចផ្តើមបង្កើតយន្តការយុត្តិធម៌អន្តរកាល ក្រៅប្រពន្ធ័តុលាការដូចជា វេទិកាសហគមន៍ ឬកិច្ចសន្ទនារវាងជនរងគ្រោះនិងជនល្មើស និងសេវាផ្តល់ ការគាំទ្រផ្សេងទៀតសម្រាប់អ្នកនៅរស់រានមានជីវិតពីសម័យកម្ពុជាប្រជាធិបតេយ្យ។ ចាប់ពីឆ្នាំ២០១១ ដោយមានកិច្ចសហប្រតិបត្តិការជាមួយអង្គការចិត្តសង្គមអន្តរវប្បធម៌ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា និងអង្គភាពគាំពារជនរងគ្រោះ បានកំពុងអនុវត្តគម្រោងរួមមួយស្តីពីស្ត្រីនិងយុត្តិធម៌អន្តរកាលក្នុង ប្រទេសកម្ពុជា។ គម្រោងនេះត្រូវបានរៀបចំឡើង ដើម្បីឱ្យស្ត្រីបានចូលរួមក្នុងដំណើរការយុត្តិធម៌ អន្តរកាល ដែលអាចជួយស្ត្រីឱ្យអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការស្វែងរកការពិត យុត្តិធម៌ពីបទឧក្រិដ្ឋ ការស្តារនីតិសម្បទា និងការធានាថាមិនមានបទឧក្រិដ្ឋបែបនេះកើតឡើងជាថ្មីទៀត។ លើសពីនេះទៀត ដោយមានការគាំទ្រផ្នែកសង្គមចិត្តសាស្ត្រ និងច្បាប់ដល់អ្នករស់រានមានជីវិត គម្រោងនេះបានរួម បញ្ចូលជាមួយសកម្មភាពផ្សព្វផ្សាយ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីអំពើហិង្សាផ្លូវភេទ និងយេនឌ័រ ក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ ដើម្បីកាន់តែបង្កើនឱ្យមានបរិយាកាសគាំទ្រដល់អ្នកនៅរស់រាន មានជីវិតបន្ថែមទៀត។

ទោះបីមានកិច្ចខិតខំប្រឹងប្រែងរបស់ អ.វ.ត.ក និងអង្គការសង្គមស៊ីវិលក៏ដោយ ក៏ការយល់ដឹង របស់អ្នកជំនាន់ក្រោយសង្គ្រាមក្នុងប្រទេសកម្ពុជា នៅមានកម្រិតអំពីប្រវត្តិសាស្ត្រនៃប្រទេសរបស់ខ្លួន។ នាពេលថ្មីៗនេះ ប្រព័ន្ធអប់រំផ្លូវការទើបតែបានបញ្ចូលមេរៀនអំពីរបបខ្មែរក្រហមទៅក្នុងកម្មវិធីសិក្សាក្នុង មុខវិជ្ជាប្រវត្តិសាស្ត្រ។ ប្រជាជនកម្ពុជាវ័យក្មេងជាច្រើនទទួលបានព័ត៌មានតិចតួច និងមួយផ្នែកអំពីរបប នេះតាមរយៈឪពុកម្តាយ មិត្តភក្តិ ឬប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដែលពេលខ្លះធ្វើឱ្យពួកគេមិនជឿ និងមាន

ការយល់ខុស។ ប្រជាជនស្ថិតក្នុងវ័យនេះ មិនសូវយល់ដឹងអំពីអំពើហិង្សាផ្លូវភេទ និងយេនឌ័រ ដែលប្រព្រឹត្តលើស្ត្រីក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យឡើយ។

# គោលដៅ និងដំណើរការ



ការស្តាប់សំឡេងស្ត្រីជាមួយមនុស្សជំនាន់ក្រោយឆ្នាំ២០១៣ ត្រូវបានរៀបចំបន្ទាប់ពីការស្តាប់សំឡេងរបស់ស្ត្រី ដែលបានរៀបចំក្នុងឆ្នាំ២០១១ និង២០១២។ វេទិកានីមួយៗត្រូវបានរៀបចំឡើងដោយប្រកាន់ខ្ជាប់តាមទម្រង់ដូចគ្នា ដែលអ្នកនៅរស់រានមានជីវិតផ្តល់សក្ខីកម្មជាសាធារណៈមុននឹងគណៈវិនិច្ឆ័យដាក់ចេញនូវសេចក្តីថ្លែងការណ៍រួមជាមួយលទ្ធផលរកឃើញនិងអនុសាសន៍។ ក្នុងឆ្នាំ២០១១ ប្រធានបទនៃវេទិកាការស្តាប់សំឡេងស្ត្រី ផ្តោតលើអំពើហិង្សាផ្លូវភេទក្នុងរបបខ្មែរក្រហមក្នុងប្រទេសកម្ពុជា។[2] ក្រៅពីប្រធានបទនេះ ការស្តាប់សំឡេងស្ត្រីតំបន់អាស៊ីប៉ាស៊ីហ្វិកឆ្នាំ២០១២[3] មានគោលដៅបង្កើនការយល់ដឹងអំពីអំពើហិង្សាផ្លូវភេទ និងយេនឌ័រក្នុងពេលមានជម្លោះ ដោយជាទូទៅតាមរយៈការស្តាប់ ការផ្តល់សក្ខីកម្មរបស់ស្ត្រីមកពីប្រទេសចំនួនបីក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។

វេទិកាទាំងបីនៃការស្តាប់សំឡេងស្ត្រី មានផលប្រយោជន៍ចំពោះកិច្ចប្រឹងប្រែងរបស់ អ.វ.ត.ក ក្នុងការដោះស្រាយបទឧក្រិដ្ឋជាច្រើនដែលបានប្រព្រឹត្តក្នុងពេលកន្លងមក។ វេទិកាទាំងនេះផ្តល់នូវយុត្តិធម៌អន្តរកាលក្រៅប្រព័ន្ធតុលាការដើម្បី៖

- ផ្តល់សិទ្ធិអំណាចដល់អ្នកនៅរស់រានមានជីវិតដែលទទួលរងអំពើហិង្សាផ្លូវភេទ និងយេនឌ័រ តាមរយៈការផ្តល់ឱកាសដល់ពួកគេក្នុងការបញ្ចេញសំឡេងពាក់ព័ន្ធនឹងបទឧក្រិដ្ឋនេះ និងបង្ហាញពីតម្រូវការ និងការទាមទាររបស់ខ្លួន
- ផ្តល់កិត្តិយសដល់អ្នកនៅរស់រានមានជីវិតឡើងវិញតាមរយៈការបង្ហាញឱ្យដឹងជាសាធារណៈអំពីភាពឈឺចាប់ ក៏ដូចជា ភាពរឹងមាំ និងសេចក្តីក្លាហានរបស់ពួកគេ
- ប្រឆាំងនឹងការមាក់ងាយ និងការរើសអើងលើអ្នកនៅរស់រានមានជីវិត តាមរយៈការលើកកម្ពស់ការយល់ដឹងអំពីផលប៉ះពាល់ដែលពួកគេជួបប្រទះ និងក្តីកង្វល់របស់ពួកគេ
- បង្កើតឱ្យមានកំណត់ត្រាប្រវត្តិសាស្ត្រកាន់តែត្រឹមត្រូវ តាមរយៈការរៀបចំឯកសារស្តីពីបទពិសោធន៍របស់អ្នកនៅរស់រានមានជីវិត។

2 របាយការណ៍ស្តីពីដំណើរការនៃការស្តាប់សំឡេងស្ត្រី ពីអំពើហិង្សាផ្លូវភេទក្រោមរបបខ្មែរក្រហម -២០១១ អាចរកបាននៅ www.gbvkr.org/publications-and-materials/reports.

3 ការស្តាប់សំឡេងស្ត្រី ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកស្តីអំពើហិង្សាផ្លូវភេទ និងយេនឌ័រពេលមានជម្លោះ - របាយការណ៍ឆ្នាំ ២០១២ អាចរកបាននៅ www.gbvkr.org/publications-and-materials/reports.

# អ្នកផ្តល់សក្ខីកម្ម



ចំណុចសំខាន់នៃការស្តាប់សំឡេងស្ត្រី គឺការផ្តល់សក្ខីកម្មរបស់អ្នកនៅរស់រានមានជីវិតដែលទទួលរងអំពើហិង្សាផ្លូវភេទ និងយេនឌ័រក្នុងរបបខ្មែរក្រហម។ រឿងរ៉ាវផ្ទាល់ខ្លួនទាំងនេះធ្វើឱ្យយើងយល់ដឹងបន្ថែមទៀតអំពីអំពើហិង្សាក្នុងពេលមានជម្លោះ និងបទពិសោធន៍ដាច់ដោយឡែកពីគ្នារបស់ស្ត្រីនិងកុមារី។ ពួកគេក៏បានបង្ហាញឱ្យឃើញអំពីភាពឈឺចាប់ ដែលកើតមានមកជាយូរដែលបង្កឡើងដោយអ្នកដែលប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះ។

តាមរយៈទំនាក់ទំនងជាមួយភាគីដើមបណ្តឹងរដ្ឋប្បវេណី ដោយមានកិច្ចសហប្រតិបត្តិការអង្គការសង្គមស៊ីវិលផ្សេងៗ និងការងារក្នុងសហគមន៍ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជាបានកំណត់ និងចុះជួបស្ត្រីជាអ្នកនៅរស់រានមានជីវិតជាច្រើននាក់ ដែលទទួលរងអំពើហិង្សាផ្លូវភេទនិងយេនឌ័រ ដើម្បីឱ្យចូលរួមក្នុងការស្តាប់សំឡេងស្ត្រីឆ្នាំ២០១៣។ ក្នុងចំណោមស្ត្រីដែលស្ម័គ្រចិត្តស្ត្រីបួននាក់ត្រូវបានជ្រើសរើសឱ្យផ្តល់សក្ខីកម្ម។ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជាបានចាប់ផ្តើមដំណើរការរៀបចំ និងណែនាំស្ត្រីទាំង នេះទៅតាមនីតិវិធី ដោយមានការគាំទ្រពីអ្នកចិត្តសាស្ត្ររបស់យើងគឺ កញ្ញា ស្រៀ រដ្ឋា។

ដើម្បីរៀបចំស្ត្រីទាំងនេះក្នុងការផ្ដល់សក្ខីកម្មក្នុងពេលជំនុំជម្រះ បុគ្គលិកនៃក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា៖

- បានផ្ដល់ព័ត៌មានដល់ស្ត្រីទាំងនេះ អំពីអ្វីដែលពាក់ព័ន្ធក្នុងការស្ដាប់សំឡេងស្ត្រីជាមួយមនុស្សជំនាន់ក្រោយ និងដំណើការនៃវេទិកានេះ
- បានសាកសួរជាផ្លូវការទៅស្ត្រីទាំងនេះអំពីការឯកភាពយល់ព្រមក្នុងចូលរួមវេទិកានេះ
- បានផ្ដល់ការអប់រំអំពីចិត្តសាស្ត្រសម្រាប់ធ្វើប្រតិកម្មតប ដែលអាចមានក្នុងពេលផ្ដល់សក្ខីកម្ម និងយុទ្ធសាស្ត្រដោះស្រាយ
- បានចងក្រងឯកសារស្ដីពីរឿងរ៉ាវរបស់ស្ត្រី និងបានជួយពួកគេក្នុងការអនុវត្តការផ្ដល់សក្ខីកម្ម
- បានពិនិត្យតាមដានប្រតិកម្មតប និងបទពិសោធន៍ស្ត្រីទាំងនេះបន្ទាប់ការជំនុំជម្រះ។

បន្ទាប់ពីការស្ដាប់សំឡេងរបស់ស្ត្រីជាមួយមនុស្សជំនាន់ក្រោយ អ្នកផ្ដល់សក្ខីកម្មបានបង្ហាញថា វេទិកានេះមានឥទ្ធិពលវិជ្ជមានក្នុងជីវិតរបស់ពួកគេ។ ស្ត្រីបានលើកឡើងថាមុនពេលបង្ហាញសក្ខីកម្មរបស់ពួកគេ ពួកគេមានអារម្មណ៍អស់សង្ឃឹម និងអន់ចិត្តដោយសារនាពេលកន្លងមក ពួកគេមិនដែលមានឱកាសក្នុងការនិយាយអំពីអំពីហិង្សាដែលបានប្រព្រឹត្តលើពួកគេ។ ពួកគេពិតជាចង់និយាយជាសាធារណៈ នៅចំពោះមុខហ្វូងមនុស្សជាច្រើនសម្រាប់ពេលដំបូង។ បន្ទាប់ពីការចូលរួមរបស់ពួកគេក្នុងការស្ដាប់សំឡេងស្ត្រីជាមួយមនុស្សជំនាន់ក្រោយ ស្ត្រីទាំងបួននាក់បានបង្ហាញអំពីភាពធូរស្បើយ និងអារម្មណ៍ដែលទទួលបានការគាំទ្រពីអ្នកចូលរួមស្ដាប់ ជាពិសេសនៅពេលដែលបានឃើញអ្នកចូលរួមស្ដាប់យំ បន្ទាប់ពីបានស្ដាប់សក្ខីកម្ម និងមានការអាណិតអាសូរចំពោះពួកគាត់។ ពួកគាត់រីករាយដែលទទួលបានកម្លាំងចិត្ត និងការលើកទឹកចិត្តក្នុងការឱ្យអ្នកដទៃបានដឹងអំពីបទពិសោធន៍របស់ខ្លួន។ ស្ត្រីទាំងបួននាក់យល់ស្របថា ការចូលរួមក្នុងការស្ដាប់សំឡេងរបស់ស្ត្រីជាមួយមនុស្សជំនាន់ក្រោយផ្ដល់អត្ថប្រយោជន៍សម្រាប់ពួកគាត់ ពីព្រោះពួកគាត់មានឱកាសក្នុងការបង្ហាញអំពីក្ដីកង្វល់ និងតម្រូវការរបស់ខ្លួន។ ពួកគេសង្ឃឹមថាវេទិកានៃការស្ដាប់សំឡេងរបស់ស្ត្រីជាមួយមនុស្សជំនាន់ក្រោយនឹងរៀបចំទៀតក្នុងពេលអនាគតសម្រាប់អ្នកនៅរស់រានមានជីវិតជាច្រើននាក់ទៀត ដែលកំពុងរង់ចាំឱកាសក្នុងបញ្ចេញមតិ និងជំរុញស្ត្រីឱ្យចូលរួម។



# គណៈវិនិច្ឆ័យ

ការស្តាប់សំឡេងរបស់ស្ត្រីជាមួយមនុស្សជំនាន់ក្រោយឆ្នាំ២០១៣ បានបង្វែរការយកចិត្តទុកដាក់របស់ខ្លួនទៅលើមនុស្សកើតក្រោយសម័យសង្គ្រាម ដោយមានការចូលរួមពីនិស្សិតមកពីមហាវិទ្យាល័យ និងមុខជំនាញខុសៗគ្នាទៅក្នុងដំណើរការវេទិកាទាំងមូល។ គណៈវិនិច្ឆ័យក្នុងឆ្នាំកន្លងមកមានសមាសភាពពីអ្នកជំនាញជាតិ និងអន្តរជាតិលើផ្នែកអំពើហិង្សាផ្លូវភេទនិងយេនឌ័រ សម្រាប់គណៈវិនិច្ឆ័យនៃការស្តាប់សំឡេងស្ត្រីជាមួយមនុស្សជំនាន់ក្រោយឆ្នាំ២០១៣នេះ សមាសភាពចូលរួមមានមកពីអ្នកស្ម័គ្រចិត្តដែលជានិស្សិតមហាវិទ្យាល័យ ដើម្បីដាក់ចេញសេចក្តីថ្លែងការណ៍របស់គណៈវិនិច្ឆ័យ។



ក្នុងការរៀបចំតួនាទីរបស់ពួកគេ ក្រុមការងារដែលមាននិស្សិតចំនួនដប់ប្រាំពីរនាក់ទទួលបានការបណ្តុះបណ្តាលពីអ្នកជំនាញរយៈពេលពីរថ្ងៃពីប្រធានបទពាក់ព័ន្ធ។ ប្រធានបទទាំងនេះរួមមានបញ្ហាយេនឌ័រអំពើហិង្សាផ្លូវភេទ និងយេនឌ័រ ផលប៉ះពាល់ចិត្តសង្គមសម្រាប់ជនរងគ្រោះ ប្រវត្តិខ្មែរក្រហម និងការសរសេរសេចក្តីថ្លែងការណ៍នៃការវិនិច្ឆ័យពីក្រុមការងារដែលនិស្សិតចំនួនប្រាំមួយនាក់ត្រូវបានជ្រើសរើស ដោយមិត្តរួមក្រុមរបស់ខ្លួនឱ្យធ្វើជាសមាជិកគណៈវិនិច្ឆ័យ។ សមាជិកគណៈវិនិច្ឆ័យមានឱកាសជួប និងស្គាល់អ្នកផ្តល់សក្ខីកម្មមុននឹងស្តាប់ការស្តាប់សំឡេងស្ត្រីជាមួយមនុស្សជំនាន់ក្រោយ។ អ្នកផ្តល់ប្រឹក្សាចំនួនពីរនាក់គឺកញ្ញា កាស៊ូមី ណាកាហ្គាវ៉ា Kasum Nakagawa ជាសាស្ត្រាចារ្យនៃសាកលវិទ្យាល័យបញ្ញាសាស្ត្រ និងលោក ដួង សាវន ជាអ្នកសម្របសម្រួលគម្រោង GBV អំពើហិង្សាផ្លូវភេទរបស់ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជាបានផ្តល់ការណែនាំដល់ក្រុមការងារដែលជានិស្សិត តាមរយៈដំណើរការធ្វើសេចក្តីព្រាងសេចក្តីថ្លែងការណ៍នៃការវិនិច្ឆ័យ។

ក្នុងវគ្គពិនិត្យតាមដានបន្ទាប់ពីវេទិកាស្តាប់សំឡេងរបស់ស្ត្រីជាមួយមនុស្សជំនាន់ក្រោយ និស្សិតដែលជាសមាជិកគណៈវិនិច្ឆ័យបានបង្ហាញការពេញចិត្ត និងការថ្លែងអំណរគុណដែលបានចូលរួមក្នុងវេទិកានេះ។ សមាជិកគណៈវិនិច្ឆ័យសម្តែងការអរគុណជាពិសេសចំពោះអ្នកផ្តល់សក្ខីកម្ម ដែលបានចែករំលែករឿងរ៉ាវផ្ទាល់ខ្លួន និងប្រាប់អំពីភាពលំបាកក្នុងការផ្តល់សក្ខីកម្មជាសាធារណៈ។ ពួកគេបានលើកទឹកចិត្តឱ្យស្ត្រីមានសេចក្តីក្លាហានក្នុងការធ្វើបែបនេះ។ ពួកគេបានផ្តោតចិត្តទុកដាក់លើសារៈសំខាន់នៃការលើកកម្ពស់ការយល់ដឹងអំពីអំពើហិង្សាផ្លូវភេទនិងយេនឌ័រ ដែលបានប្រព្រឹត្តក្នុងរបបខ្មែរក្រហម និងបានលើកឡើងថាពួកគេមិនដែលបានដឹងអំពីបញ្ហាទាំងនេះ មុននឹងមានវេទិកានៃការស្តាប់សំឡេងស្ត្រីជាមួយមនុស្សជំនាន់ក្រោយឡើយ។ សមាជិកគណៈវិនិច្ឆ័យបានប្តេជ្ញាអនុវត្តសកម្មភាពជាច្រើនដូចជា ការធ្វើបទបង្ហាញអំពីវេទិកានៃការស្តាប់សំឡេងស្ត្រីជាមួយមនុស្សជំនាន់ក្រោយក្នុងថ្នាក់រៀន ឬពិភាក្សាអំពីវេទិកាជាមួយមិត្តរួមថ្នាក់។



# សក្ខីកម្ម

ក្នុងអំឡុងការស្តាប់សំឡេងស្ត្រីឆ្នាំ២០១៣ អ្នកនៅរស់រានមានជីវិតចំនួនបួននាក់បានផ្តល់សក្ខីកម្មអំពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេទាក់ទងនឹងអំពើហិង្សាផ្លូវភេទ និងយេនឌ័រក្នុងរបបខ្មែរក្រហម។ ការផ្តល់សក្ខីកម្មរបស់ពួកគេ ធ្វើឡើងតាមរយៈការឆ្លើយតបទៅនឹងសំណួរដែលសួរដោយមន្ត្រីកម្មវិធីរបស់ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា កញ្ញា ហង្ស ចរិយា ។ ជំពូកបន្ទាប់និយាយអំពីសេចក្តីសម្រង់សង្ខេបដែលបានកែសម្រួលពីការថ្លែងការណ៍នៃសក្ខីកម្មរបស់ពួកគេ។

## មុំ វន់



ខ្ញុំឈ្មោះ មុំ វន់ មានអាយុ៦៥ឆ្នាំ របររកស៊ីលក់ថ្នាំកញ្ចប់ជាមួយនិងការស៊ីឈ្នួលកាប់ដំឡូងឱ្យគេ។

### ជីវិតនៅក្រោមរបបខ្មែរក្រហម

ពេលខ្មែរក្រហមបានចូលមករស់នៅក្នុងភូមិនៅដំបូង គេអត់អីទេល្អណាស់ ក្រោយមកបាន២ខែពួកគេបានប្រមូលទ្រព្យសម្បត្តិអ្នកស្រុកទាំងអស់ ហើយផ្ទះធំខ្ញុំគេរើធ្វើជាសហករណ៍ គេថាពេលស្រុកស្រួលបួលគេឱ្យខ្ញុំវិញ..រហូតហៅឪពុកម្តាយខ្ញុំទៅសម្លាប់អស់ថាជាមេឃុំគាត់ជាអ្នកភ្លេងការសោះ ក៏គេយកគាត់ទៅសម្លាប់ទៅ។ រហូតមកខ្ញុំក៏ត្រូវគេឱ្យធ្វើការក្នុងសហករណ៍ យើងមានកូនខ្ចី១ខែ ជាការងារស្រាល។ បច្ចុប្បន្នខ្ញុំនៅសល់កូន៥នាក់ក្នុងចំណោមកូន១៦នាក់។ នៅអំឡុងពេលសម័យខ្មែរក្រហម កូនរបស់ខ្ញុំចំនួន៦នាក់បានស្លាប់ដោយសារតែពួកគេគ្មានអ្វីបរិភោគ។

### បទពិសោធន៍ នៃអំពើហិង្សាផ្លូវភេទ និងយេនឌ័រ

សម័យនោះគេបានបង្ខំចិត្តខ្ញុំឱ្យរៀបការនៅការដ្ឋានរែកដីរួចមកគេហៅខ្ញុំមកសួរថា៖ *_ឥឡូវមិត្តឯងត្រូវតែរៀបការ ហើយមិត្តដែលការនោះមិនដែលស្គាល់គ្នាមិនដែលស្រលាញ់សោះ ហើយឱ្យខ្ញុំយកអ្នកបុរសមានកូន៨នាក់ហើយខ្ញុំមិនយកទេ។_ អត់យកក៏ត្រូវតែយកដែរ រួចមកបានមួយសារកន្លងផុតបាន៤ថ្ងៃគេហៅទៀតសួរហើយសួរទៀត ដល់ថ្ងៃរៀបបណ្តោយ ៦០គូរក្នុងមួយថ្ងៃមានមាន់១គត់ផ្កា២ចូ២ ដើមដាក់ពីមុខ, ៦០គូរអង្គុយដំរៀបជួរគ្នាមានតែស្បែកជើង១គូរ គេឲ្យទ្រូបអង្គុយរួចហើយឡើងប្តេជ្ញាចិត្តទៅរ៉ាប់រងគ្នាទៅ ថាយើងសុខចិត្តថែរក្សាគ្នាមួយជីវិតទៅខំបង្ករបង្កើតផល បើមានកូន

យើងចិញ្ចឹមកូន។

ដល់ពេលម៉ោង៣ជិតភ្លឺគេឲ្យយើងមកផ្ទះ ដល់ពេលយប់ដែលយើងរៀបដេកហើយគូភាគីដែលប្តី ប្រពន្ធ ដែលអត់ស្រលាញ់គ្នានឹងនិយាយថា យើងការៗសិនទៅដល់យ៉ាងមិចៗចាំបែកគ្នា យើងស្រុះស្រួលនឹងគ្នា អត់ដឹងថាមានឈ្លបវាពួនស្តាប់ក្រោមផ្ទះទេគេឡើងទៅថា *"ត្រូវតែផ្សំដំណេកនៅកន្លែងនេះ" កាំភ្លើងគេភ្ជង់គេឲ្យយើងដេកទៅ។ "គ្រាន់តែដេកឲ្យគេរុកក៏ពិបាកដែរ" នេះជាភាសា របស់វាប្រើមកលើខ្ញុំ... ខ្ញុំតមាត់ទៅវិញថា "ឲ្យគេរុកម៉េច? " គេថា "ដេកឲ្យគេចុយ!"* វាឱ្យផ្សំដំណេកនិងដួចដាក់បាជ្រូកបារចឹងវាឈរមើលថាដេកឬក៏អត់។ ដល់ពេលផ្សំដំណេកហើយវាថា "ទៅ!ទៅវាចុយគ្នាហើយ យើងចុះចេញ"។ វាតាមមើលនេះហើយយប់ស្អែកវាមកតាមទៀត វាខ្លាចយើងយល់ព្រមតែមួយយប់ និងដល់៦យប់ដែលគ្រប់កំណត់ដល់វាឈប់មកតាម។ ពេលដឹងថាមានកូនហើយវាបំបែកប្តីឲ្យទៅឆ្ងាយទៀត វាអត់ឲ្យនៅជុំគ្នាទេអំណាចផ្តាច់ការវា។ ដល់ពេលឆ្លងទន្លេឲ្យប្តីមកតែ២ថ្ងៃទេ ឲ្យទៅវិញមិនបាច់នៅទេ។

### សាក្សីនៃអំពើហិង្សាផ្លូវភេទ និងយេនឌ័រ

មានឈ្មោះដិនគេចោទថារៀតណាមដោយចោទថាខុសសីលធម៌ គេចាប់យកទៅថាស្លាប់តែទៅដល់វត្តកំពុងក្តីគេមករំលោភសិនបានគេសម្លាប់... ហើយពួកខ្ញុំរែកដីនៅវត្តឃើញផ្ទាល់ភ្នែក ហើយក៏អត់ហានឮម៉ាត់ដែរខ្លាចថាងាប់ទាំងអស់គ្នាសុខចិត្តរែកដីទៅមក។ បន្ទាប់ពួកវាម្នាក់ចាប់ដៃ ចាប់ជើង អាខ្លះរំលោភទៅអាខ្លះចាប់ដៃចាប់ជើងទៅ.. រួចហើយវាចងដៃទៅក្រោយ ចងហើយវារះឆ្អឹងខ្នង ហើយវាយកប្រម៉ាត់ទៅត្រាំស្រា វាកើតឡើងឆ្ងាយប្រហែល១០មពីកន្លែងដែលយើងឈរ។ នារីនោះបានស្រែកហើយពួកយើងបានឃើញតែមិនហ៊ានយកចិត្តទុកដាក់មើលទេ យើងគ្រាន់ក្រឡេកមើលពីចម្ងាយតែមិនហ៊ានមើលចំទេ យើងបន្តធ្វើការធម្មតា។

មានកម្មាភិបាលម្នាក់អាចមានមិត្តនារី៥នាក់ កម្មាភិបាលតែងតែចងអង្រឹងដេកនៅខាងលើ ពួកមិត្តនារីចងមុងដេកខាងក្រោម ពេលគេត្រូវការគេកេះមួយទៅ.. ចូលទៅក្នុងមួយទៅ ហើយចេញមកវិញយំមួយ ទៅអត់ហានស្រែកថាយ៉ាងណាទេខ្លាចគេសម្លាប់ចោល ហៅក្នុងមួយយប់៥នាក់ (មិត្តសៀមានអំណាចធំណាស់) មិត្តសៀកម្មាភិបាល គេធំណាស់គេចង់អីអ្នកណាក៏បាន ស្រី៥នាក់ត្រូវបានគេហៅទៅម្តងមួយៗរៀងរាល់យប់។

ឈ្មោះមិត្តថេនៗមានអាយុ១៨ដែរ ហៅទៅឆ្ងាយពីកន្លែងដែលខ្ញុំដេក ២០ម៉ែត្រ ឮសំឡេងស្រែកជួយផងៗ កុំឱ្យធ្វើបាបខ្ញុំ លែងខ្ញុំទៅ ឮសូរផ្ងូងក៏បាត់ទៅអត់ឃើញរហូត នៅការដ្ឋានក៏មិនឃើញដែរ.. គ្នាស្លាប់ទៅហើយមិចបានឃើញ បានថាអំណាចផ្តាច់ការរបស់គេក៏វាធំអាងគេកម្មាភិបាល អាងគេអ្នកធំគេចង់បានអ្នកណាគេយកអ្នកហ្នឹង។

រៀងរាល់មួយខែឬពីរសប្តាហ៍ម្តង  ក្រុមនារីៗ៥នាក់តែងតែមកជំនួសក្រុមស្ត្រីចាស់ៗ៥នាក់នោះ។ ស្ត្រីទាំងនោះមិនមែនមកពីតំបន់យើងទេ ពួកគេមករស់នៅក្នុងសហករណ៍របស់ពួកយើង។ ពួកគេអាយុ ប្រហែល២១, ២២, ២៥ឆ្នាំ ប្រហែលចឹង។ ខ្ញុំឃើញគេខ្សឹកខ្សួល និងយំ ហើយមានម្នាក់និយាយថាពួកយើងត្រូវបានរំលោភដោយខ្មែរក្រហម។ ពួកគេរំលឹកខ្ញុំកុំឱ្យប្រាប់រឿងនេះដល់អ្នកណា បើមិនអញ្ចឹងទេយើងអាចត្រូវគេសម្លាប់ មានតែពេលនោះទេដែលខ្ញុំបានឮ និងបាននិយាយជាមួយពួកគេពីរឿងនេះ។ ពួកវាធ្វើរៀងរាល់២ថ្ងៃម្តង។ ស្ត្រី៥នាក់នោះត្រូវបានគេបំបាត់ចេញបន្ទាប់ពីត្រូវបានរំលោភ៣ដង។

ក្នុងឆ្នាំ១៩៧៧ មានគេរៀបការនៅក្នុងកងរៀបចំដោយខ្មែរក្រហម។ មានខ្មែរក្រហមម្នាក់គេអាងគេជាកម្មាភិបាលនិងជាអ្នកធំ គេហៅអ្នកដែលរៀបនោះ ស្រីដែលជាគូរភាគីជាប្រពន្ធគេហៅថាយកទៅផ្សំដំណេកមុន ដល់ផ្សំដំណេកហើយនឹងយកទៅឱ្យប្តីវិញ តែប្តីនោះអត់យកទេគេបាញ់ងាប់ទាំងពីរ។

## ផលប៉ះពាល់ និង ប្រតិកម្ម



ខ្ញុំមិនខឹងអ្នកគូភាគីប៉ុន្មានទេ តែខ្ញុំខឹងអាអ្នកឱ្យផ្សំដំណេក ដែលបង្ខំដាក់ឱ្យខ្ញុំផ្សំដំណេកជាមួយគ្នា។ ខ្ញុំមានការឈឺចាប់ត្រង់ហ្នឹង ដែលខ្មាសអស់ខ្លួនវាក៏ខ្មាសខ្លួនឯងចេះតែលាក់ទុក ឥឡូវខ្ញុំមកបើកកកាយឲ្យអស់ចំពោះឧក្រិដ្ឋកម្មរបស់វា ដែលបានធ្វើលើរូបខ្ញុំឲ្យបងប្អូនរួមជាតិ និងអន្តរជាតិ និស្សិតបញ្ញាវន្ត កូនចៅជំនាន់ក្រោយយល់ដឹងថា របបនោះវាបានធ្វើអំពើមកលើខ្ញុំច្រើនបំផុត។

វាធ្វើនេះដើម្បីឱ្យស្លាប់តែយើងមិនស្លាប់ បើយើងមិនព្រមរួមដំណោកវាសម្លាប់យើងចោល ដូច្នេះយើងខំតែធ្វើទៅខាំមាត់សង្កត់ចិត្តដើម្បីរស់។ ខ្ញុំផ្តាំផ្ញើសំឡេងស្ត្រីខ្មែរ ដើម្បីបកស្រាយឱ្យបងប្អូនដឹង ឱ្យក្មេងដឹងថារបបនោះវាល្អប៉ុណ្ណាអាក្រក់ប៉ុណ្ណា។ ខ្ញុំមានអារម្មណ៍ខ្មាស់អៀនខ្លាំង និងសោកស្តាយនៅក្នុងជីវិត គឺសំណាងអាក្រក់បានមកជួបនូវរឿងបែបនេះ។ ឈឺចាប់ក្នុងជីវិតនេះទោះបីជាស្លាប់ក៏មិនអាចបំភ្លេចដែរ។ ខ្ញុំមិនដែលប្រាប់រឿងនេះដល់អ្នកណាទេ ព្រោះខ្ញុំអៀនខ្មាស់ ប៉ុន្តែខ្ញុំមិនអាចលាក់ទុកបានទេ ត្រូវតែប្រកស្រាយឱ្យបងប្អូនដឹង។ ខ្ញុំខំពង្រឹងស្មារតីដើម្បីរកស៊ីចិញ្ចឹមកូន ដើម្បីជីវិតរបស់ខ្ញុំ សង្គ្រោះកូនខ្ញុំឱ្យរួចផុតពីការមានទុក្ខ។

## សំណូមពរ និងសារ

មានសំណូមពរសាលាក្តីថាឱ្យឆាប់កាត់ទោសជនជាប់ចោទទាំងអស់ឱ្យបានឆាប់រហ័ស។ សូមផ្តាំផ្ញើទៅគ្រប់គ្នា ខំធ្វើយ៉ាងណាដើម្បីកុំឱ្យមានឧក្រិដ្ឋកម្មនេះកើតឡើងទៀត ហើយខំបង្រួបបង្រួមគ្នាដើម្បីសាងជិវិតថ្មីកុំឱ្យកើតឡើងម្តងទៀត។

## យ៉ាំ ឡាស់



ខ្ញុំមកពីភូមិអូរជ្រៅ ឃុំអូរជ្រៅ ស្រុកព្រៃនប់ ក្រុងកំពង់សោម ខ្ញុំជាជនជាតិខ្មែរឥស្លាម មានអាយុ៧៦ឆ្នាំ។

### ជីវិតនៅក្រោមរបបខ្មែរ ក្រហម

ខ្ញុំរស់នៅភូមិអូរជ្រៅ ឃុំអូរជ្រៅ។ សម័យខ្មែរក្រហមខ្ញុំប្រកបការងារ គេដាក់ទិសដៅនៅស្រុក៣៧ លើកដីទំនប់ ធ្វើស្រែ រែកដីដោយអត់អាហារហូរគ្រប់គ្រាន់។ គ្រួសារខ្ញុំនិងកូនគេយកទៅសម្លាប់នៅឆ្នាំ ១៩៧៧ ដើមឆ្នាំនោះ តែខ្ញុំមិនបានឃើញកូនខ្ញុំមិនដឹងស្លាប់នៅកន្លែងណាដែរ។ ពេលខែភ្លឺ ដូចថ្ងៃខ្ញុំឃើញគេចងប្រជាជនដាក់ម៉ាខ្សែៗ ៧នាក់ ៥នាក់ ៣នាក់អីក៏មានគេយកទៅវៃចោល។ ខ្ញុំមានបងប្អូន១៣នាក់ តែឥឡូវនៅតែ៣នាក់ទេ បងប្រុសខ្ញុំត្រូវបានគេយកទៅហើយដុតទាំងរស់។

ដោយសារតែខ្ញុំធ្វើការធ្ងន់ពេក ខ្ញុំឈឺហើមនៅក្នុងការដ្ឋាន។ ខ្ញុំបានឡើងមកដេកពេទ្យ មកដល់លើខ្មែរក្រហមអត់ឱ្យខ្ញុំដេកពេទ្យទេ គេបង្ខំឱ្យខ្ញុំធ្វើការឱ្យខ្ញុំកាប់ជីកហើយរែកដី។ ដល់ពេលកាប់ទៅខ្ញុំលុងដីក្រោមនិងដល់ដីខាងលើបាក់មកលើខ្ញុំ ហើយបានគេសែងខ្ញុំយកទៅពេទ្យ។ ខ្ញុំក៏ដេកពេទ្យនឹងយូរថ្ងៃ តែជើងខ្ញុំហើមខ្លួនហើម គ្មានថ្នាំព្យាបាលយើងទេមានតែទឹកដូងគេចាក់ឱ្យរាល់ថ្ងៃ គ្មានបាត់អីទាំងខ្លួនដៃជើងហើមទាំងអស់មានសល់អីនោះទេ។ មេកងគេថា មិត្តឯងដេកពេទ្យយូរហើយអត់ចេញចឹង? គេថាត្រូវតែចេញ ហើយខ្ញុំក៏ចេញពីពេទ្យ ពេលចេញមកខ្ញុំធ្វើអីអត់កើតទេ ខ្ញុំអត់មានផ្ទះសម្បែងអីទេ។ ខ្ញុំក៏នឹកឃើញក៏ទៅសុំផ្ទះប្អូនជីដូនមួយដេក។

### បទពិសោធន៍នៃអំពើហិង្សាផ្លូវភេទ និងយេនឌ័រ

ឆ្នាំ១៩៧៧មានយប់មួយប្រហែលជាម៉ោង១០ មានខ្មែរក្រហមម្នាក់បានមកហៅខ្ញុំឱ្យចេញពីផ្ទះ។ ខ្ញុំបានសួរវាថា *ហៅខ្ញុំធ្វើអី? វាថាមិត្តឯងចុះមកនេះ ពេលចុះមកដីខ្ញុំឆ្លើយថា "មានការអីមិត្តពូ?" វាចោទថាខ្ញុំចង់ទៅយួន *ខ្ញុំថាខ្ញុំអត់មានចង់ទៅណាចង់អីទេ** វាក៏បណ្តើរខ្ញុំប្រហែល៣០ម៉ែតពីផ្ទះ។ ដល់ទីនោះវាចាប់ផ្តើមរុញខ្ញុំឱ្យដេកនៅគល់ដូង វាប្របាច់កខ្ញុំដល់ពេលដែលខ្ញុំផិតដាច់ខ្យល់និងហើយវាក៏លែង វាក៏សម្រាតសារុងខ្ញុំ វារំលោភនឹងដូចគោដៅដោះមិនដូចប្តីប្រពន្ធ ខ្ញុំឈឺចុកចាប់ណាស់ខ្លួនប្រាណខ្ញុំគ្មានស្រាកស្រានកន្លែងណាទេ ខ្ញុំកូនខ្ចីផង។ កាលវារំលោភខ្ញុំដល់ពេលហើយវានិយាយ

ថា *កុំទៅនិយាយប្រាប់អ្នកណា បើនិយាយប្រាប់អ្នកណា បើមិត្តឯងនិយាយអីសម្លាប់ចោល* ថ្ងៃនោះខ្ញុំខ្លាច ហើយខ្ញុំមិនឱ្យបងប្អូនឬមិត្តណាដឹងពីរឿងខ្ញុំកើតឡើងយប់នោះទេ។

ដល់ពេលវារំលោភហើយក៏វាយកដៃខ្វេះខ្វាស (ប្រដាប់ភេទ) ខ្ញុំនិងបោះពេលដែលធ្លាក់មកវិញ និងខ្ញុំមិនដឹងប្រវែងប៉ុន្មានទេ ព្រោះខ្ញុំអត់ដឹងខ្លួនទេស្មានតែវាសម្លាប់ខ្ញុំចោលហើយមិនដឹងទេ ក្រោយលើកបោះខ្លួនខ្ញុំក៏ដួលត្រឡប់ត្រលិនឈឺហើមទាំងមុខទាំងខ្វាស់ (ប្រដាប់ភេទ) ខ្ញុំមិនដឹងខ្លួនដល់ពេលប្រហែលម៉ោង៤ភ្លឺ ខ្ញុំឮមាន់រងាវខ្ញុំក៏ខំប្រឹងវាមកផ្ទះប្អូនជីដូនមួយនិងប្រហែល៣០ម៉ែត្រ។ មកដល់ប្អូនខ្ញុំភ្ញាក់ផ្អើលព្រោះវាគិតថា គេយកខ្ញុំទៅសម្លាប់បាត់ហើយ វាសួរថា *ណាអើយ!* *អូបងឯងមកវិញហើយអី? គេយកបងឯងទៅធ្វើអី ស្មានតែគេយកបងឯងទៅសម្លាប់ចោលបាត់ហើយ ខ្ញុំឆ្លើយថា* *អត់ទេ!* * រួចវាសួរតទៀតថា ចុះគេយកបងឯងទៅធ្វើអី!* ខ្ញុំប្រាប់ថា *គេយកអញទៅរំលោភ*។ រួចក៏អោបគ្នា២នាក់បងប្អូនទៅនៅលើផ្ទះ មិនហាននិយាយអីដែរ ចាំភ្លឺចាំនិយាយគ្នា កុំនិយាយខ្លាចគេសម្លាប់យកទៅសម្លាប់ចោល។

ដល់ភ្លឺឡើងខ្ញុំទៅរកសុំបាយចុងភៅគេគេអត់ឲ្យ *គេសួថានៅកងណា?* ខ្ញុំថា *នៅកងមិត្តពិន* គេចាំមើលមិត្តពិនមកបើចង់បានបាយ។ ដល់ថ្ងៃម៉ោង១១គេឡើងមកពីរែកដីទាំងអស់គ្នាហើយមេចុងភៅប្រាប់មេកងថា *កូនក្រុមមិត្តពិនឯងវាយ៉ាងម៉េច បានអត់ទៅធ្វើការ* ខ្ញុំថា *ខ្ញុំទៅអត់រួចទេ ព្រោះខ្ញុំនិងឈឺព្រោះ ថាខ្ញុំហើមទាំងអស់ទាំងមុខទាំងដៃជើង* ដល់គេខឹងខ្ញុំមិនធ្វើការ គេវៃខ្ញុំ៣ដងអង្រែក ហើយថាមិត្តឯងម៉េចមិនទៅធ្វើការ?។ ខ្ញុំទៅអត់រួច រួចវាយកដងវែងបុកខ្វាស (ប្រដាប់ភេទ) ខ្ញុំពីរបីដងនៅមុខមនុស្សជាច្រើន ខ្ញុំឈឺចាប់ណាស់។ អត់មាននរណាហ៊ានជួយទេ អ្នកខ្លះណាថាយើងស៊ីពលកម្មគេ គេថាឲ្យបុកឱ្យងាប់ចុះ អាខ្លះណាគេអាណិតចឹងទៅ គេថាអាណិតគាត់ណាស់បើគាត់ធ្វើមិនកើតគាត់ហើមដល់ថ្នាក់ហ្នឹង ហើយនៅធ្វើបាបគាត់អីទៀត ឯអាខ្លះណាថាយើងស៊ីពលកម្មគេ គេថាឲ្យបុកឱ្យងាប់ចុះ។

## ផលប៉ះពាល់ និង ប្រតិកម្ម

រាល់ថ្ងៃផ្លូវកាយខ្ញុំនៅឈឺក្នុងខ្លួនគ្មានកំលាំងកំហែងអីទេ ស្គមរីងរៃ ឈឺចិត្ត ក្នុងប្រដាប់ភេទនិងចេះតែចុកអួល ចេះតែទិញថ្នាំលេបរាងធូរយូរៗម្តង។

ខ្ញុំមានអារម្មណ៍ខឹងខ្លាំង ឈឺចាប់ក្នុងខ្លួនខ្ញុំមានអារម្មណ៍ខ្មាស់គេ ខ្ញុំចេះតែលាក់ទុកជាង៣០ឆ្នាំ ទាំងឆ្នាំ១៩៧៩ ដល់ពេលដាក់ពាក្យបណ្តឹងអង្គការនិងហៅទៅណាក៏ចេះតែទៅ អត់មានឱ្យគេដឹងទេ ខ្មាសគេ តែឥឡូវខ្ញុំនឹងបើកឲ្យកូនចៅជំនាន់ក្រោយដឹងថា របបប៉ុលពតនិងវាធ្វើអំពើអាក្រក់ប៉ុន្មាន ឲ្យដឹងលឺទាំងក្រៅប្រទេសក្នុងប្រទេសថាវាមានរដ្ឋអំណាចធ្វើបាបប្រជាជនយ៉ាងណា។

## សំណូមពរ និងសារ



ខ្ញុំសម្រេចចិត្តនិយាយរឿងនេះ ព្រោះខ្ញុំបានចូលរួមកម្មវិធីនេះកាលលើកមុនខ្ញុំឃើញអន្តរជាតិ និងជនរងគ្រោះផ្សេង មានគេក្មេងជាងខ្ញុំតែគេហ៊ានបកអាក្រាតខ្លួនគេអស់គ្មានសល់ ដល់ខ្ញុំមានអាយុ៧០ជាង ហើយខ្ញុំទុកធ្វើអី ចឹងហើយធ្វើឲ្យខ្ញុំហ៊ានបកអាក្រាធខ្លួនឯងឲ្យបងប្អូនកូនចៅដឹងទាំងអស់ឲ្យដឹងថា គេក្មេងគេហ៊ាននិយាយ ខ្ញុំចាស់មានអីខ្លាចនិយាយបើកចំហរឲ្យបងប្អូនកូនចៅញាតិមិត្តដឹងឲ្យអស់។

ខ្ញុំមានពាក្យពេចន៍ ចង់ផ្តាំផ្ញើទៅជនរងគ្រោះដូចខ្ញុំ សូមឲ្យហ៊ានក្លាហានឡើងនិយាយឲ្យបងប្អូនកូនចៅអស់លោកទាំងអស់ដឹងលឮបរទេសនិងក្រៅប្រទេសដឹងទាំងអស់គ្នា។ ខ្ញុំចង់ឲ្យសាលាក្តីខ្មែរក្រហមកាត់ទោសមេដឹកនាំខ្មែរក្រហមនឹងឲ្យឆាប់ ព្រោះខ្ញុំចាស់ហើយខ្លាចស្លាប់មុនមិនបានដឹង។

## ឡោះ វណ្ណា



ខ្ញុំឈ្មោះ ឡោះ វណ្ណា នៅភូមិអូរជ្រៅ ឃុំអូរជ្រៅស្រុក ព្រៃនប់ ក្រុងកំពង់សោម មីងមានអាយុ៦០ឆ្នាំ មុខរបរធ្វើស្រែ។

### ជីវិតនៅក្រោមរបបខ្មែរ ក្រហម

នៅសម័យខ្មែរក្រហមក្នុងឆ្នាំ១៩៧៥ គេជម្លៀសម្តាយខ្ញុំបងប្អូនខ្ញុំឲ្យបែកគ្នាអស់។ ផ្ទះខ្ញុំធំទូលំទូលាយ វារុះយកទៅធ្វើជង្រុកស្រូវ ហើយឲ្យទៅនៅផ្ទះខ្ទមមួយតូច រួចហើយខ្មែរក្រហមបំបិទសាសនាខ្ញុំ។ ខ្ញុំជាជនជាតិឥស្លាមមួយរូបធ្វើបាបមីង ឲ្យមីងញ៉ាំសាច់ជ្រូក វាយកវិហារមីងទៅចិញ្ចឹមសត្វជ្រូក ធ្វើជាទ្រុងជ្រូក រួចហើយវាបង្ខំមីងឲ្យលើកទំនប់ជីកប្រឡាយ បង្ខំឲ្យធ្វើស្រែ តាមអំពើចិត្តរបស់វា បង្ខំមីងឱ្យញ៉ាំសាច់ជ្រូកទៀត បើមិនញ៉ាំនិងសម្លាប់ចោល។ ខ្មែរក្រហមបំបែកខ្ញុំនិងប្តីខ្ញុំមិនឲ្យខ្ញុំទៅជួបជុំគ្នា ឲ្យទៅធ្វើការនៅសហករណ៍ផ្សេងៗគ្នា មិនឲ្យមកជិតគ្នា មិនឲ្យមកជួបគ្នាសោះ ដល់ឆ្នាំ១៩៧៧ បានវាជម្លៀសខ្ញុំមកនៅកំពង់ស្ពឺវិញ។ នៅក្នុងឆ្នាំ១៩៧៧ ដៃរគ្រួសារខ្ញុំគេឲ្យកាន់ក្របី១នឹម មានថ្ងៃមួយប្តីខ្ញុំក៏បានបាត់ខ្លួន មីងមិនដឹងថាប្តីទៅណាមកណាទេឃើញតែក្របីគាត់ ខ្ញុំមិនដឹងគាត់ទៅណាទេ នឹកឃើញថាមានតែគេយកទៅសម្លាប់គាត់ទៅបាត់រហូតដល់សព្វថ្ងៃ។

### បទពិសោធន៍នៃអំពើហិង្សាផ្លូវភេទ និងយេនឌ័រ

នៅឆ្នាំ១៩៧៧ នៅយប់មួយប្រហែលជាបានមួយអាទិត្យបន្ទាប់ពីប្តីខ្ញុំបានបាត់ខ្លួន ខ្ញុំមកពីជីកប្រឡាយវិញ ខ្ញុំហូបបាយរួចហើយចូលដេកដោយអត់បានមុជទឹក និងអត់បានប្តូរខោអាវទេ ព្រោះខ្ញុំស្តមរីងរៃអស់កម្លាំង មកដេកស្រមុកទាំងជើងខោមិនបានលាប្រលាក់សុទ្ធតែភក់។ ដល់ពេលប្រហែលម៉ោង១២យប់ មានមេកងម្នាក់វាមកហៅមីង មីងគិតថា *(អូយ! យកប្តីមីងទៅសម្លាប់ឥឡូវយកមីងទៅសម្លាប់ទៀតហើយ)*។

ខ្ញុំឮគេហៅថា មិត្តនារីៗអញ្ជើញងើបចុះមកនេះមក ខ្ញុំក៏អស់ព្រលឹងក្នុងខ្លួន ហើយនឹកឃើញថាគេយកមីងទៅសម្លាប់តែមិនដឹងថាមានរឿងអីកើតឡើងទេ មីងគ្រាន់តែនឹកឃើញថាគេយកមីទៅសម្លាប់។ ខ្ញុំក៏ចុះមកទាំងភ័យញ័រ ខ្ញុំសួរថា *តើមានការអីមិត្ត?* តែវាមិនឆ្លើយ។ ខ្ញុំឃើញវាមានកាំភ្លើង

ពូថៅ ខ្សែមួយដំធំ។ វារុញខ្ញុំឱ្យដើរទៅមុខ ហើយវាដើរពីក្រោយទៅកន្លែងមួយដែលមានដើមសេមាន់ធំមួយ ប្រហែលកន្លះគីឡូឬមួយគីឡូដីពីផ្ទះ។

ទៅដល់ដើមឈើធំនោះមានតែខ្ញុំនិងវាអត់មានអ្នកណាទេ មីងមិនដែលស្គាល់វាទេ ដឹងថាវាមេកងធំជាអ្នកចាប់ចងសម្លាប់ឱ្យថាចាមៗ។ វារុញខ្ញុំផ្តួលនៅគល់ឈើដើមសេមាន់ វាចាប់ស្រាតខោខ្ញុំចេញ ហើយខ្ញុំក៏មិនបាននឹកឃើញថាវានិងធ្វើអីខ្ញុំ គ្រាន់តែគិតថាវានិងសម្លាប់ខ្ញុំប្រហែលជាវះពោះខ្ញុំយកថ្លើម យកប្រម៉ាត់យកទៅត្រាំស្រា តែតាមពិតវាយកម្រាមដៃដាក់ចូលក្នុងប្រដាប់ភេទខ្ញុំ។

វាយកដៃរុកឆ្កៀលបុកយ៉ាងខ្លាំង ទម្រាំតែយើងឈឺអស់ចិត្ត។ រុកឆ្កៀលៗ រួចហើយវាធ្វើតាមទំនើងចិត្តរបស់វាតាមចិត្តវារួចហើយ វាផ្តាំផ្ញើរខ្ញុំថា មិត្តនារីឯងកុំប្រាប់អ្នកណា ហ៊ានតែប្រាប់គេខ្ញុំនឹងសម្លាប់មិត្តនារីឯងចោលអត់ទុកទេ។ រួចហើយខ្ញុំក៏នៅនឹងអស់កំលាំងខ្លាំងពេក មីងនៅសម្ងំនៅក្រោមដើមឈើហ្នឹងប្រហែលជាបានកន្លះម៉ោង ខ្ញុំខ្លាចវាមកវិញធ្វើបាបក៏ខំដើរត្រឡប់មកផ្ទះវិញ។ នៅម៉ោង៥ព្រឹក ខ្ញុំឮសំឡេងជួងដែលជាសម្លេងហៅប្រជាជនទៅធ្វើការ។ ខ្ញុំឈឺណាស់តែអត់ហ៊ានប្រាប់អ្នកណាគេទេ ព្រោះខ្លាចគេសម្លាប់។ ទៅធ្វើការមានបងប្អូនថាស្គាល់មិត្តនារីៗធ្វើការជាមួយគ្នាថា បងឯងជួយកោសខ្យល់ឲ្យខ្ញុំតិចមក ខ្ញុំរៀងអត់ស្រួលក្នុងខ្លួន នាងនិយាយប្រាប់ថាពូហ្នឹងហើយចាប់នាងរំលោភម្តងដែរ យើងកុំប្រាប់គេយើងលាក់ទុកដូចគ្នា។

ឥឡូវមីងហ្នឹងស្លាប់ហើយ ហើយពូនោះឈ្មោះពូសយ មេកងធ្វើនៅហ្នឹងមេមិនមែនទេគេយកទៅសម្លាប់ចោលអស់ហើយ តែវាអាងវាមេកងវាមិនឱ្យយើងនិយាយ បើមិនចឹងវានឹងសម្លាប់ចោលយើងក៏គោរពវាមិនហ៊ាននិយាយ ខ្ញុំឈឺចិត្តណាស់ដែលវារុកកកូរកកាយប្រដាប់ខ្ញុំឈឺហើម នៅខាងក្នុងធ្វើឲ្យមានជំងឺរហូតដល់សព្វថ្ងៃហ្នឹង តែខ្ញុំខំព្យាបាល។ ដល់សង្គមនេះហើយ មីងខំរកថ្នាំព្យាបាល ថ្នាំសង្កូវអីព្យាបាល មីងចេះតែប្រឹងហូបទាល់សព្វថ្ងៃ។

## សាក្សី នៃអំពើហិង្សាផ្លូវភេទ និងយេនឌ័រ

ខ្ញុំដឹងរឿងមីងឃុំឡាស់ ជាបងជីដូនមួយ។ គាត់ត្រូវបានរំលោភដោយខ្មែរក្រហម បន្ទាប់ពីគាត់បានចេញពីមន្ទីរពេទ្យហើយមកស្នាក់នៅជាមួយខ្ញុំ។ នៅយប់នោះមានទាហានម្នាក់គេមកហៅគាត់ទៅ តែខ្ញុំអត់ដឹងគាត់ត្រូវបានគេយកទៅណាទេ។ ខ្ញុំគ្រាន់តែគិតថាខ្មែរក្រហមយកគាត់ទៅសម្លាប់ចោល។ ខ្ញុំអាណិតគាត់ណាស់ខ្ញុំខ្លាចណាស់។ នៅពេលព្រឹកខ្ញុំឃើញគាត់ត្រឡប់មកវិញ ខ្ញុំសួរគាត់ អូ!

បងឯងមកវិញហើយអី? គេយកបងឯងទៅធ្វើអីគាត់ប្រាប់ថា *គេយកគាត់ទៅរំលោភ*។ រួចក៏ទៅចូលដេកទាំងឈឺចុកចាប់។

## ផលប៉ះពាល់ និង ប្រតិកម្ម

មិនសប្បាយក្នុងចិត្តទេ ខ្ញុំមិនអាចបំភ្លេចបាន ខ្ញុំនៅតែខ្លាចនិងខឹង ។ ខ្ញុំចង់ឲ្យអង្គការជួយដោះស្រាយទាំងក្នុងប្រទេសក្រៅប្រទេសប្អូនៗមីងមាទាំងអស់ ជួយដោះស្រាយមីងឱ្យបានធូរស្រាលនៅក្នុងចិត្ត កុំឲ្យពិបាកក្នុងចិត្ត៣០ឆ្នាំជាងហើយ មីងនៅតែមានការឈឺចាប់និងការដែលគេចាប់រំលោភ។ មីងមិនដែលប្រាប់អ្នកណាបានទាល់តែសោះនៅសម័យហ្នឹង ដល់ពេលឥឡូវមីងអាចនិយាយប្រាប់ ម្តាយមីង ប្អូនមីងដែលមីងអាចនិយាយប្រាប់។ ពេលនឹកឃើញថាមីងបានស្តាប់ប៉ុស្តិ៍សំឡេងស្ត្រីនិយាយរឿងដែលដូចមីងដែរ មីងក៏ចង់ឲ្យអង្គការណាហៅមីងនិយាយពីរឿងផ្លូវភេទ និងមីងគិតចង់និយាយដូចប៉ុស្តិ៍ផ្សាយចឹងដែរ ឲ្យបងប្អូនជនរួមជាតិពុទាំងអស់និងប្អូនៗ និស្សិតជំនាន់ក្រោយឲ្យវាដឹងមីងឥឡូវ៦០ឆ្នាំហើយ មីងក៏អស់កេរ្តិ៍អស់ខ្មាសហើយចេះតែប្រាប់ដល់ប្អូនៗបានដឹងបានពុទាំងអស់គ្នាទៅ។

## សំណូមពរ និងសារ

សូមឲ្យប្អូនៗទាំងអស់និងអង្គការទាំងអស់ពូមាមីងដែលមកចូលរួមស្តាប់ក្នុងថ្ងៃនេះឬអង្គការក្នុងនិងក្រៅប្រទេសទាំងអស់ធ្វើយ៉ាងម៉េចជួយគាំទ្រមីង និងអ្នកផ្សេងទៀត ដែលរងគ្រោះពីការរំលោភក្នុងសម័យខ្មែរក្រហម។ កុំរើសអើងពួកយើង ព្រោះខ្ញុំមិនអាចជៀសផុតទេកាលនោះ។ សូមជួយគាំទ្រខ្ញុំ និងកុំឲ្យរបបខ្មែរក្រហមកើតជាលើកទីពីរទៀត កុំឲ្យមានកើតសង្គ្រាមខ្មែរក្រហមជាលើកទីពីរទៀត។



## ជា ណុំ



ខ្ញុំមកពីខេត្តពោធិ៍សាត់ ឃុំស្នាមព្រះ ស្រុកបាកានមានអាយុ៧៦ ឈ្មោះជាណុំ។

### ជីវិតនៅក្រោមរបបខ្មែរ ក្រហម

ខ្ញុំរស់នៅភ្នំពេញពុកខ្ញុំគាត់ធ្វើប៉ូលីសសក្ត័ពីរ ខ្ញុំនៅចំការមនដល់ចេញពីចំការមនទៅប្តីខ្ញុំបើកឡាន។ យើងធ្លាប់ជាគ្រួសារដែលធូរធារ។ ឪពុកខ្ញុំជាអ្នកមាន និងជាអ្នកឧបត្ថម្ភគ្រួសារ។

ពេលអាពតចូលភ្នំពេញ ខ្ញុំត្រូវបានបង្ខំចេញទៅខេត្តតាកែវស្រុកកំណើតខ្ញុំ។ ខ្ញុំចេញពីភ្នំពេញទៅខេត្តតាកែវគេបង្ខំឲ្យធ្វើការ និងទាំងគ្រួសារតែបែកគ្នាទាំងអស់ពុកខ្ញុំម្តាយខ្ញុំប្តីខ្ញុំកូនខ្ញុំបងថ្លៃស្រី ត្រូវបានទទួលរងពីរបបព្រៃផ្សៃយប់ឃ្នង់នោះ។ ពួគគេត្រូវបានធ្វើបាបវាយ និងចាប់យកទៅពេទ្យ។ គេស្នាក់នៅតែមួយអាទិត្យរួចស្លាប់អស់ហេតុអី? ពួកគេបានឲ្យថ្នាំទន្សាយលេប និងមិនអនុញ្ញាតឲ្យផឹក និងហូបអាហារទេ។

ខ្មែរក្រហមដឹងថាឪពុកខ្ញុំធ្លាប់ធ្វើជាមន្ត្រីប៉ូលីសគេបានសម្លាប់គាត់។ ខ្មែរក្រហមសម្លាប់អ្នកគ្រប់គ្នាឲ្យតែជាអតីតអ្នកមន្ត្រីរដ្ឋាភិបាល។ ខ្ញុំនៅសល់បងប្អូន៦នាក់។ នៅអម្លុងសម័យខ្មែរក្រហមខ្ញុំត្រូវបានគេបង្ខំឲ្យធ្វើស្រែខ្ញុំរងនូវភាពអត់ឃ្លាន។ កូនរបស់ខ្ញុំ៤នាក់ស្លាប់។ ឪពុកខ្ញុំស្លាប់មុន រួចហើយប្រហែលកន្លះខែក្រោយមកចូលឆ្នាំ១៩៧៧ ម្តាយខ្ញុំត្រូវខ្មែរក្រហមបង្ខំឲ្យធ្វើការរួចស្លាប់គេមិនឲ្យសាកសពមកខ្ញុំទេខ្ញុំ មិនដឹងថាគេយកគាត់ទៅណាទេ។

### បទពិសោធន៍នៃអំពើហិង្សាផ្លូវភេទ និងយេនឌ័រ

យប់មួយបន្ទាប់ពីខ្ញុំត្រឡប់មកពីធ្វើការនៅឯស្រែវិញ នៅពីខាងជើងភូមិបារាយណ៍វិហារពីរនិងដល់ហើយឃើញគេហាលអំបិលយប់ឡើងខែភ្លឺថ្ងៃមួយពេច ខ្ញុំក៏ធ្វើពុតជាឈឺនោមខ្ញុំលួចអំបិលគេមួយដៃ រួចក៏បានលួចអំបិល ស្រាប់តែពេលនោះនាងមុំគេនៅឈឺនោមក្បែរខ្ញុំគេក៏ស្រែកថា *ចោរលួចអំបិលៗ* ដល់ខ្ញុំរកទំលាក់គេចាប់ដៃខ្ញុំជាប់ដើម្បីគេឲ្យឃើញភស្តុតាង ដល់ពេលរួចហើយគេហៅឈ្លប២នាក់មកចាប់ខ្ញុំ។ ឈ្លបគេមកមានគ្នា២នាក់តូចៗ គេឲ្យខ្ញុំដើរដំណើរផ្អែ ខ្ញុំក៏ចេះតែវាចឹងទៅ ទៅដល់ក្រោមដើមត្នោតមួយ ក៏ជួបនឹងអ្នកឡើងត្នោតឈ្មោះគៀម វាក៏និយាយទៅឈ្លបនោះថា "***ហែង!ដើរចេញទៅទុកឲ្យអញ អញធ្វើបាបវាទាល់តែងាប់មីហ្នឹង***"។

ពេលឈ្លបទៅបាត់ទៅគេចាប់ផ្ដើមធ្វើបាបខ្ញុំ គេស្រាតសារុងហើយគេរំលោភហើយគេវាយខ្ញុំ២ដំបងនៅពិការដល់រាល់ថ្ងៃ និងត្រកៀកនេះគេថាខូចថាលមួយចំហៀង ហើយដល់ឥឡូវព្យាបាលថ្នាំខ្មែរអញ្ចឹងទៅបានគ្រាន់បន្តិច ហើយដល់ពេលវារំលោភហើយវាវ៉ៃខ្ញុំ២ដំបងហើយ វាកាត់ស្លឹកញ៉េញគ្របលើខ្ញុំពេញប្រហែលជាវាគិតថាខ្ញុំស្លាប់ហើយ។ ខ្ញុំឈឺប្រដាប់ភេទនិងធ្លាក់ឈាម។ ខ្ញុំអត់ដឹងខ្លួនទេប្រហែលជាម៉ោង៣ជាងក៏មិនដឹងដែរខ្ញុំក៏វាលូនទៅផ្ទះវិញ។

ខ្ញុំពេលនោះក៏ទើបតែកូនង៉ែតខ្ចីដែរ អ្នកមើលកូនខ្ញុំគឺជាម្ដាយមីងខ្ញុំឈ្មោះយាយសែ គាត់ឆ្ងល់ថាខ្ញុំទៅណាក៏បាត់យូរម្ល៉េះ មានគេខ្សឹបប្រាប់គាត់ថាវាលួចអំបិលគេ គេយកទៅមន្ទីរហើយ រីឯខ្លួនឯងខំវាទាំងឈឺចាប់ ហើយជិតដល់ផ្ទះហើយជួបឈ្លបមួយទៀត វាក៏សួរថាមិត្តឯងមកពីណា ខ្ញុំថាខ្ញុំទៅផ្ទះវិញខ្ញុំអត់ស្រួលខ្លួន។ គេចាប់ខ្ញុំទៅដាក់ក្នុងគុកនៅបារាយ២ដដែល ដែលក្នុងនោះមានអ្នកទោសជាច្រើន។ ខ្ញុំជាប់ក្នុងគុកនោះតែ២ថ្ងៃទេដោយសារតែធ្លាក់ឈាមពេក ទើបគណៈស្រុកគេឃើញឲ្យចេញមកវិញ។

## ផលប៉ះពាល់ និង ប្រតិកម្ម

ធ្លាប់នឹកគិតថាចង់ធ្វើបាបវាដែរ ចង់សងសឹកវាដែរ តែខ្ញុំចូលរៀនសូត្រកាន់សីលកាន់ទានទៅខ្ញុំក៏មិនអាចទៅសងសឹកវាទេ កុំឱ្យមានកម្មពៀរ ខ្ញុំក៏ឈប់មានគំនិតចងកម្មពារចេញពីខួរក្បាលខ្ញុំ។ តាមពិតខ្ញុំបានឈឺចាប់ច្រើនឆ្នាំហើយ តែថ្ងៃនេះវាប្រសើរព្រោះខ្ញុំចង់ចែករំលែកវា។ ក្នុងបំណងរបស់ខ្ញុំចង់ឲ្យប្រជាជនរៀនសូត្រពីការឈឺចាប់ ទៅជាការការពារកុំឲ្យវាកើតឡើងម្ដងទៀត។

ខ្ញុំនៅឈឺជើងនៅឈឺត្រកៀកខាងឆ្វេង ក្នុងចិត្តមិនសូវឈឺចាប់ទេដូចថាវាយូរឆ្នាំទៅហើយ ប៉ុន្តែពេលនេះនឹកឃើញគឺឈឺចាប់វិញ។ តស៊ូដើម្បីកូនដើម្បីខ្លួនឯងដើម្បីកិត្តិយសខ្ញុំត្រូវតែព្យាយាម។ ចង់ឲ្យបងប្អូនជាជនរងគ្រោះផ្សេងទៀតធ្វើដូចខ្ញុំ។

## សំណូមពរ និង សារ

សូមផ្ដាំដល់អ្នកមានរឿងដូចខ្ញុំឲ្យបានតស៊ូឡើង ត្រូវតែយល់ដឹង និងកត់ត្រារឿងយើងសម្រាប់ក្មេងជំនាន់ក្រោយ។ ឲ្យជួយកាត់ទោសខ្មែរក្រហមឱ្យបានទាន់ខ្ញុំមើលឃើញ ឱ្យខ្ញុំបានដឹងថាវាធ្វើបាបយ៉ាងម៉េចខ្លះសូមឲ្យកាត់ទោសភ្លាមៗទៅ។



ខ្ញុំមានវិធីក្នុងការសម្របសម្រួលខ្លួនឯង។ ខ្ញុំមិនដឹងថាតើមានមនុស្សប៉ុន្មាននាក់ត្រូវបានទទួលរងពីការឈឺចាប់នោះទេ ប៉ុន្តែខ្ញុំចង់លើកទឹកចិត្តដល់ជនរងគ្រោះ និងអ្នករស់នៅផ្សេងទៀត សូមមានសេចក្តីក្លាហានក្នុងការបំបែកភាពស្ងៀមស្ងាត់ អញ្ចឹងអ្នកអាចមានអារម្មណ៍ថាផ្លូវចិត្តអ្នកប្រសើរជាងមុន។ ខ្ញុំសូមសំណូមពរឲ្យរដ្ឋាភិបាលជួយដោះស្រាយឱ្យបានឆាប់ កុំឱ្យសង្គមយើងកើតមានឡើងជាលើកទី២។ សំណើរបស់ខ្ញុំ គឺខ្ញុំចង់ឃើញអ្នកទាំងនោះនាំយកមកកាត់ទោស។ ខ្ញុំ៧៦ហើយ ក្រែងលរខ្ញុំមិនបានឃើញ បានដឹងពីយុត្តិធម៌ បើមិនបានឃើញបានដឹងក៏ឃើញក្នុងកាសែតឲ្យអស់ចិត្តដែរ ខ្ញុំចង់ឲ្យកូន និងចៅ របស់ខ្ញុំបានស្តាប់សំឡេងនៃការឡើងនិយាយដោយផ្ទាល់របស់ខ្ញុំនេះ និងកត់ត្រាទុក។ ខ្ញុំចង់លើកទឹកចិត្តមនុស្សទាំងអស់ សូមឲ្យឆ្លាត និងរៀនសូត្រកុំឲ្យដូចជំនាន់ខ្ញុំ ហើយខ្ញុំចង់ឱ្យអ្នកបំបាត់នៃការរងទុក្ខនោះ។

# សំឡេងពីអ្នកចូលរួម

បន្ទាប់ពីការធ្វើសក្ខីកម្ម កម្មវិធីបានបើកឱកាសឲ្យអ្នកចូលរួមបានសួរសំណួរឬផ្តល់ជាយោបល់លើអ្វីដែលពួកគេបានឮ។ ក្នុងអំឡុងពេលនៃការបើកការពិភាក្សាជាចំហនេះ មានអ្នករស់រានមានជីវិតម្នាក់ពីអំពើហិង្សាផ្លូវភេទក្នុងរបបខ្មែរក្រហមមានភាពក្លាហាន ដើម្បីចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់និងត្រូវបានកត់ត្រាក្នុងនេះ :



ខ្ញុំរស់នៅភូមិអូរ ឃុំដូនជុំ ស្រុកបាកាន ខេត្តពោធិ៍សាត់ ខ្ញុំក៏ជាជនរងគ្រោះក្នុងរបបខ្មែរក្រហមអស់រយៈពេល ៣ឆ្នាំ ៨ខែ ២០ថ្ងៃដូចជនរងគ្រោះដទៃទៀតដែរ។ លើកទី១ អង្គការពិភពលោកបានជួយមកណែនាំនិងលើកទឹកចិត្តខ្ញុំ ហើយបាននាំខ្ញុំឱ្យស្គាល់សាលាក្តីបានពីរដង។ សូមទោសខ្ញុំភ័យញ័រ។

ខ្ញុំសូមរៀបរាប់អំពីប្រវត្តិរស់នៅរបស់ខ្ញុំផ្ទាល់នៅក្នុងរបបខ្មែរក្រហម ខ្ញុំរស់នៅភូមិកន្តាង ឃុំកន្តាង ស្រុកបាកាន ខេត្តពោធិ៍សាត់។ ពេលនោះពួកគេឱ្យខ្ញុំធ្វើប្រឡាយជាមួយប្តីរបស់ខ្ញុំស្មើនឹងជីវិត ហើយគេឱ្យខ្ញុំរែកថ្ម។ ប្តីរបស់ខ្ញុំធ្វើស្ពាន។ ថ្ងៃមួយនៅពេលបាយថ្ងៃត្រង់ គេគ្រប់គ្នាមកហូបបាយអស់ហើយ តែនៅមិនឃើញប្តីខ្ញុំមកហូបបាយទៀត ឃើញតែប្តីគេ ពេលនោះខ្ញុំសុំគេទៅបត់ជើង រួចគេថាយល់ព្រម ខ្ញុំទៅហើយត្រឡប់មកហូបបាយវិញ។ រួចហើយខ្ញុំទៅកន្លែងកសាងស្ពានរកប្តីខ្ញុំ។ ពេលនោះមានតាចាស់ម្នាក់ប្រាប់ខ្ញុំ ប្តីរបស់នាងគេវាយនឹងដំបងរែកថ្មអូសចូលស្ទឹងស្លាប់បាត់។ ខ្ញុំលែងខ្លាចអ្វីទាំងអស់ ខ្ញុំបានស្រែកថា "នរណាដែលបានសម្លាប់ឪពុកម្តាយបងប្អូន និងប្តីរបស់ខ្ញុំសូមមកយកខ្ញុំទៅណាក៏ទៅចុះ"។

ពេលនោះមានមេកងពល ជាមេទាហានគេបាននិយាយថា *"ហេប្រពន្ធអាក្បត់ យើងស្រឡាញ់នាងយូរហើយ តើនាងព្រមការជាមួយខ្ញុំឬអត់?"* ខ្ញុំឆ្លើយថាទេតើខ្ញុំអាចស្រឡាញ់អ្នក ទទួលអ្នកយ៉ាងម៉េច? *រៀបការស្មើក្នុងមួយយប់៣០ទៅ៤០គូ គ្មានសាច់ញាតិបងប្អូនព្រះសង្ឃអាចារ្យចូលរួមអញ្ចឹងនោះ* ខ្ញុំបានស្រែកនិងយំ ហើយមេគេនិយាយថា ចាប់ស្រីនោះជនក្បត់នោះដាក់ច្រវាក់ រួចខ្ញុំត្រូវគេដាក់ច្រវាក់។

ខ្ញុំបានយំស្រែកគ្រប់ពេលវេលារកឪពុកម្តាយនិងបងប្អូនស្រីប្រុសរបស់ខ្ញុំតែអត់ប្រយោជន៍ទេ។ ខ្ញុំត្រូវបានគេដាក់ច្រវ៉ាក់។ ខ្ញុំអាចមើលឃើញតែមេឃនិងផ្កាយ។ នៅពេលដែលខ្ញុំបើកភ្នែករបស់ខ្ញុំទាំងអស់ អ្វីដែលខ្ញុំបានឃើញគឺមានផ្កាយ។ ខ្ញុំត្រូវបានគេដាក់ច្រវ៉ាក់ដោយសារតែខ្ញុំមិនយល់ព្រមរៀបការជាមួយប្រធាន ចឹងខ្ញុំត្រូវបានគេដាក់ច្រវ៉ាក់។ វាបានបញ្ជាឲ្យកូនចៅវាផ្សេងទៀតចូលមកលេងដោះខ្ញុំលេងប្រដាប់ភេទខ្ញុំ គាបដោះខ្ញុំ។ រួចមកពួកវាបានប្រើជារបស់មួយដើម្បីធ្វើបាបប្រដាប់ភេទរបស់ខ្ញុំ។

ជើងរបស់ខ្ញុំត្រូវបានហែកចេញពីគ្នា ហើយខ្ញុំបានសន្លប់ប្រាំបីដង។ ពេលខ្ញុំនៅក្នុងគុកសែនមហាវេទនា គ្មានកន្ទេលខ្នើយ ស្រមោចខាំដៃនិងជើងរបស់ខ្ញុំជាប់ច្រវ៉ាក់ ក្នុងមួយយប់ខ្ញុំសន្លប់៨ដង។ ខ្ញុំបាននិយាយថា ខ្ញុំនឹងខាំលិង្គរបស់ពួកគេ ប៉ុន្តែបន្ទាប់មកពួកគេបានដាក់លិង្គពួកគេចូលទៅក្នុងមាត់របស់ខ្ញុំ។ ខ្ញុំបានព្យាយាមគេចពីវា។ ខ្ញុំគ្រាន់តែបន់ស្រន់ឲ្យព្រះជួយខ្ញុំ។ ខ្ញុំត្រូវបានស្រមោចនិងសត្វល្អិតខាំ។ ពួកគេបានមកម្តងទៀតវាបានថើបនិងរំលោភខ្ញុំ។ ពួកគេថើបខ្ញុំម្តងហើយម្តងទៀត។ នៅពេលនោះខ្ញុំមិនមែនស្តមទេខ្ញុំបានព្យាយាមតទល់ ខ្ញុំបានស្បថទៅពួកគេខ្ញុំបានបណ្តាសារនៅពួកគេ។ ពួកគេមិនគ្រាន់តែមិនខ្វល់ទេ ពួកគេបានមកហើយថើបខ្ញុំហើយលេងជាមួយសុដន់របស់ខ្ញុំម្តងហើយម្តងទៀត។

ខ្ញុំសូមអំពាវនាវដល់និស្សិត អ្នកនៅរស់រានមានជីវិត អ្នកចូលរួមប្រជាជនកម្ពុជា និងអង្គការសង្គមស៊ីវិលសូមជួយចងចាំរឿងនេះ និងស្វែងរកយុត្តិធម៌សម្រាប់ខ្ញុំនៅឆ្នាំ2013។ ខ្ញុំអំពាវនាវទៅអង្គការក្រៅរដ្ឋាភិបាល ដែលបានរៀបចំព្រឹត្តិការណ៍នេះ បន្តជួយដល់ជនរងគ្រោះនៅទូទាំងប្រទេស។ ប្រជាជនត្រូវបានសម្លាប់បន្ទាប់ពីរំលោភ ហើយនៅពេលដែលស្ត្រីមានផ្ទៃពោះនាងត្រូវបានគេបោះចោលនៅក្នុងភ្លើងនិងដុតទាំងរស់ ហើយគ្មាននរណាម្នាក់ចាត់ការរឿងនេះឡើយ។ ឥឡូវនេះយើងមានអង្គការក្រៅរដ្ឋាភិបាល យើងមានមន្ត្រីសាធារណៈ យើងមានអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ ដែលបានជួយរដ្ឋាភិបាលឱ្យនៅឆ្ងាយពីខ្មោះច្រវ៉ាក់។ ខ្ញុំចង់ឲ្យសិស្សបន្តសិក្សា។ មិនត្រូវឆាប់ជឿគេទេ ត្រូវក្លាហាន។ ខ្ញុំលើកទឹកចិត្តដល់ជនរងគ្រោះកម្ពុជា និងសិស្សនិស្សិត ខ្ញុំសូមជូនពរឱ្យអ្នកមានអាយុវែងនិងសុភមង្គលជារៀងរហូត។

# សេចក្តីថ្លែងការណ៍របស់គណៈវិនិច្ឆ័យ




និស្សិតចំនួនប្រាំមួយនាក់ដែលជាសមាជិកគណៈវិនិច្ឆ័យបានស្តាប់សក្ខីកម្ម និងបានសួរសំណួរអ្នកផ្តល់សក្ខីកម្ម។ បន្ទាប់ពីការផ្តល់សក្ខីកម្ម សមាជិកគណៈវិនិច្ឆ័យបានបង្ហាញពីការកោតសរសើរចំពោះអ្នកផ្តល់សក្ខីកម្ម ដែលបានបង្ហាញពីភាពរឹងមាំ ក្នុងការប្រាប់ពីបទពិសោធន៍របស់ខ្លួន ភាពក្លាហានក្នុងការនិយាយការពិត និងសណ្តានចិត្តក្នុងចែករំលែករឿងរ៉ាវផ្ទាល់ខ្លួន។

ក្រុមការងារដែលមានសមាជិកចំនួន១០នាក់ ជានិស្សិតមកពីមហាវិទ្យាល័យខុសៗគ្នា បានផ្តល់ការគាំទ្រដល់គណៈវិនិច្ឆ័យ ក្នុងការរៀបចំសេចក្តីថ្លែងការណ៍នៃការវិនិច្ឆ័យដែលមានសេចក្តីលម្អិតដូចខាងក្រោម៖



*សមាជិកនៃគណៈវិនិច្ឆ័យ និងក្រុមការងារ៖ ឆេង ចាន់នីតា / ឈុន សៀកវ៉ា / អ៊ីន វដ្ឋា / កែវ បុប្ផាឧសភា / កែវ រតនា / ខុន ចន្ថា / ឃុត អិច / អាឌី ម៉ៃ មីស៊ីរ៉ន្ទូ / ណៃ ឧត្តម / ណុច ស្រីនាង / ផៃ សភាបញ្ញា / ស៊ឹម ហាក់ / ស ឈីវហ្គិច / រីម សុវណ្ណារី / ថន ភារ៉ូ / ឃុន ស្រីនិច*

# អត្ថបទពេញនៃសេចក្តីថ្លែងការរបស់គណៈវិនិច្ឆ័យ



## សេចក្តីផ្តើម

របបខ្មែរក្រហមដែលប្រជាជនទូទៅនិងសាកលលោកបាន ដឹងគឺជារបបប្រល័យពូជសាសន៍មួយដែលបានសម្លាប់ប្រជាជនអស់ជិត២លាននាក់ ក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩។ របបមួយនេះត្រូវគេចាត់ទុកជារបបខ្មៅងងឹតបំផុតក្នុងប្រវត្តិសាស្រ្តខ្មែរ។ នៅសម័យនោះប្រជាជនខ្មែរជាពិសេសពលរដ្ឋនៅរាជធានីភ្នំពេញ និងតាមទីប្រជុំជននានាទាំងអស់ ត្រូវបង្ខំជម្លៀសទៅកាន់តំបន់ដាច់ស្រយាលនៅតាមបណ្តាខេត្តដើម្បីធ្វើស្រែចំការ។ ប្រជារាស្រ្តទូទៅត្រូវបានពួកខ្មែរក្រហមបង្ខំឱ្យធ្វើការហួសកម្លាំងដោយផ្តល់នូវអាហាររូបត្ថម្ភតិចតួចស្ទើរតែមិនអាចទ្រទ្រង់សភាពរាងកាយបាន។ ជាងនេះទៅទៀតពលរដ្ឋក៏បានជួបនៅសោកនាដកម្មដ៏ជូរចត់ជាច្រើនទៀត និងការរំលោភសិទ្ធិគ្រប់រូបភាពយ៉ាងព្រៃផ្សៃដូចជាការរំលោភសិទ្ធិរស់រានមានជីវិត សិទ្ធិក្នុងការជ្រើសរើសគូស្រករ និងការចោទប្រកាន់ប្រជាជនស្លូតត្រង់ថាជាខ្មាំង រួចយកទៅដាក់ទណ្ឌកម្មនិងសម្លាប់ជាដើម។ ក៏ប៉ុន្តែមានរូបភាពនៃអំពើហិង្សាមួយរបស់ខ្មែរក្រហមដែលនៅតែស្ថិតនៅជាអាថ៌កំបាំងនោះគឺអំពើហិង្សាយេនឌ័រ។

អំពើហិង្សាយេនឌ័រ គឺជាអំពើហិង្សាដែលបង្កឡើងលើជនណាម្នាក់ដោយសារតែយេនឌ័ររបស់ពួកគេ។ ពាក្យយេនឌ័រមិនមែនសំដៅលើភេទរបស់មនុស្សទេ (ទោះបីពួកគេជាបុរស ឬស្រ្តីពីកំណើតក៏ដោយ) ប៉ុន្តែយេនឌ័រសំដៅលើគំនិតដែលត្រូវបានបង្កើតឡើងក្នុងសង្គម អំពីអ្វីដែលវាមានអត្ថន័យចំពោះបុរស ឬ ស្រ្តី (តួនាទីនិងអាកប្បកិរិយាអ្វីខ្លះ ដែលសង្គមយល់ថាសមស្រប និងគុណតម្លៃអ្វីខ្លះដែលដាក់លើបុរស និងស្រ្តី ក្មេងប្រុស និងក្មេងស្រី)។

ហិង្សាយេនឌ័រ គឺជាពាក្យមួយដែលរួមបញ្ចូលទង្វើហិង្សា ដែលបង្កឲ្យជនរងគ្រោះទទួលគ្រោះថ្នាក់ ផ្នែករាងកាយ ផ្លូវភេទ និងផ្លូវចិត្ត។ ហិង្សាទាំងនេះរួមមាន ការគំរាមកំហែង ការវាយដំ អំពើហិង្សាក្នុងគ្រួសារ ការរំលោភសេពសន្ថវៈនិងការបំពារបំពានផ្លូវភេទ អំពើហិង្សាផ្លូវចិត្ត និងសេដ្ឋកិច្ច អំពើហិង្សាពាក់ព័ន្ធនឹងជំនូនពីខាងស្រី (ចំណងដៃពីខាងស្រីឲ្យទៅកូនកម្លោះពេលរៀបការ) អំពើហិង្សាទាក់ទិននឹងការកេងប្រវ័ញ្ច ការបៀតបៀនកេរ្តិ៍ខ្មាស និងការគំរាមកំហែងនៅទីកន្លែងធ្វើការ ឬសាលារៀន ការជួញដូរស្រ្តី ការធ្វើអាជីវកម្មផ្លូវភេទ ការបង្ខំឲ្យរៀបការ ការបង្ខំឲ្យមានផ្ទៃពោះ និងការបង្ខំឲ្យធ្វើពេស្យាចារ។

ការសិក្សាស្រាវជ្រាវជាបន្តបន្ទាប់ ជាពិសេសគឺការស្រាវជ្រាវរបស់សាស្រ្តចារ្យ Kasumi Nakagawa និងក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជាដែលបានបញ្ជាក់ថា មានករណីការប្រើអំពើហិង្សាលើយេនឌ័រជាច្រើនបានកើតមានក្នុងរបបខ្មែរក្រហម។ ករណីទាំងនោះរួមមានការរំលោភសេពសន្ថវៈ ការរំលោភហើយសម្លាប់ ការរំលោភបូក និងការរំលោភតាមរយៈការបង្ខំឱ្យរៀបការជាដើម។

ដោយឡែកចំពោះជនរងគ្រោះវិញ ទោះបីជារយៈពេលជាង៣០ឆ្នាំបានកន្លងទៅក៏ដោយក៏ការឈឺចាប់ទាំងនោះនៅតែបន្តកើតមានរហូតមកដល់សព្វថ្ងៃ ចំណែកឯយុត្តិធម៌ពិតប្រាកដនៅតែមិនទាន់បានផ្តល់ជូនដល់ជនរងគ្រោះនៅឡើយ។ ជាងនេះទៅទៀតអ្វីដែលគួរឲ្យសោកស្តាយបំផុតនោះ គឺអំពើហិង្សាយេនឌ័រនារបបខ្មែរក្រហម ពុំសូវមានការចាប់អារម្មណ៍ពីសំណាក់សាលាក្តីខ្មែរក្រហម រាជរដ្ឋាភិបាល ក៏ដូចជាអង្គការពាក់ព័ន្ធនានាប៉ុន្មាននោះទេ និងជាពិសេសគឺយុវជនពុំបានដឹងអំពីរឿងនេះ។ ហេតុនេះហើយ ទើបក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា បានបង្កើតនូវកម្មវិធីការស្តាប់សំឡេងស្ត្រីជាមួយមនុស្សជំនាន់ក្រោយឆ្នាំ២០១៣ ដែលស្តីអំពី "អំពើហិង្សាយេនឌ័រក្រោមរបបខ្មែរក្រហម" ក្នុងគោលបំណងស្វែងរកយុត្តិធម៌ដល់ជនរងគ្រោះ តាមរយៈការផ្តល់ឱ្យពួកគាត់មានឱកាសទម្លាយអាថ៌កំបាំង និងនិយាយពីរឿងរ៉ាវពិតរបស់ពួកគាត់ ស្តីពីអំពើហិង្សាយេនឌ័រជាសាធារណៈ។ ជាងនេះទៅទៀត កម្មវិធីក៏នឹងផ្តល់ជាគំនិត ចំណេះដឹងថ្មី និងគំរូដល់ពលរដ្ឋខ្មែរជាពិសេសយុវជន បានដឹងឮ គិតពិចារណា និងចូលរួមក្នុងសកម្មភាពស្វែងរកយុត្តិធម៌ដល់ជនរងគ្រោះ ពីអំពើហិង្សាយេនឌ័រក្នុងរបបខ្មែរក្រហម ព្រមទាំងចូលរួមយ៉ាងសកម្មក្នុងការលុបបំបាត់អំពើហិង្សាយេនឌ័រក្នុងពេលបច្ចុប្បន្ន និងអនាគត។

## ការរកឃើញ

កម្មវិធីការស្តាប់សំឡេងស្ត្រីឆ្នាំនេះ មានការចូលរួមធ្វើជាគណៈវិនិច្ឆ័យដោយយុវជនដែលមកពីបណ្តាសាកលវិទ្យាល័យនានាក្នុងនោះរួមមាន៖ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា។

ក្រោយពីបានធ្វើការស្រាវជ្រាវស៊ីជម្រៅ និងសិក្សាលើប្រធានបទអំពើហិង្សាប្រឆាំងយេនឌ័រ ព្រមទាំងស្តាប់នូវរាល់សក្ខីកម្មនានាដែលជនរងគ្រោះ ក៏ដូចជាសាក្សីបានធ្វើការរៀបរាប់រួចមក ក្រុមគណៈវិនិច្ឆ័យបានធ្វើការកត់សម្គាល់ឃើញថា អំពើហិង្សាយេនឌ័រនារបបខ្មែរក្រហមភាគច្រើនគឺបានកើតលើស្ត្រី ប៉ុន្តែក៏មានជនរងគ្រោះជាបុរសផងដែរ។ ស្ត្រីរងគ្រោះគឺជាជនជាតិខ្មែរអ៊ីស្លាម និងជនជាតិផ្សេងទៀត។ គណៈវិនិច្ឆ័យក៏បានរកឃើញ និងយល់ឃើញថា របបកម្ពុជាប្រជាធិបតេយ្យគឺជារបបមួយដែលបានចាត់ទុកការបំពារបំពានផ្លូវភេទ គឺជាទង្វើខុសសីលធម៌ ហើយបើជនណាហ៊ានប្រព្រឹត្តិនឹងមានទោសដល់ស្លាប់។ តាមរយៈសក្ខីកម្ម គណៈវិនិច្ឆ័យបានពិនិត្យឃើញថា ភាគច្រើននៃអ្នកប្រព្រឹត្តិនូវអំពើដែលខុសសីលធម៌ទាំងនោះ គឺជាក្រុមខ្មែរក្រហមដែលជាអ្នកមានឋានៈ និងអំណាច។ ដូច្នេះមានន័យថា អ្នកហាមក៏ជាខ្មែរក្រហម រីឯអ្នកប្រព្រឹត្តិក៏ជាខ្មែរក្រហម ឯចំណែកអ្នកទទួលរងគ្រោះគឺប្រជាជន

ទន់ខ្សោយ ស្លូតត្រង់ ដែលរស់ទាំងវេទនា។ ជាលទ្ធផលប្រព័ន្ធនៃការគ្រប់គ្រងខាងលើ ពុំបានផ្ដល់យុត្តិធម៌សមរម្យណាមួយដល់ជនរងគ្រោះដោយសារអំពើហិង្សាឡើយ។

ជាការពិតណាស់បន្ទាប់ពីបានទទួលរងគ្រោះពីអំពើព្រៃផ្សៃទាំងនោះ ជនរងគ្រោះពុំមានលទ្ធភាពអាចការពារ និងតតាំងជាមួយអ្នកប្រព្រឹត្តិអំពើទាំងនោះបានទេ។ ហើយជនរងគ្រោះបានត្រឹមតែទទួលរងនូវការឈឺចាប់មកលើខ្លួនទាំងផ្លូវកាយនិងផ្លូវចិត្តរហូតមកដល់បច្ចុប្បន្ននេះ។ ជនរងគ្រោះដែលបានទទួលរងនូវអំពើព្រៃផ្សៃទាំងនោះមានអារម្មណ៍ភ័យខ្លាច ឈឺចិត្តនិងខ្មាសអៀនជាខ្លាំង នៅពេលដែលនរណាម្នាក់បានដឹងពីអាថ៌កំបាំងរបស់គាត់ ហើយរូបភាពនៃអំពើទាំងនោះនៅតែបន្តដក់ជាប់ក្នុងអារម្មណ៍ដោយមិនអាចបំភ្លេចបាន។ ជនរងគ្រោះក៏មានបញ្ហាផ្លូវកាយផងដែ បន្ទាប់ពីត្រូវបានជនដៃដល់រំលោភបំពានផ្លូវភេទ រហូតដល់បច្ចុប្បន្ននេះ ស្នាមរបួសនេះនៅតែធ្វើឲ្យជនរងគ្រោះមានការឈឺចាប់ឥតស្រាកស្រាន។ ជាការពិតណាស់ ទំហំនៃការរំលោភបំពានលើសិទ្ធិមនុស្សនាសម័យនោះមានទំហំធំ ប៉ុន្តែយុត្តិធម៌ពិតពុំទាន់បានផ្ដល់ឱ្យជនរងគ្រោះនៅឡើយទេរហូតមកដល់ពេលបច្ចុប្បន្ននេះ។

ក្នុងចំណោមជនរងគ្រោះទាំង៤រូបដែលយើងបានស្ដាប់ មាន២នាក់ជាជនរងគ្រោះដោយផ្ទាល់ និង២នាក់ផ្សេងទៀតជាជនរងគ្រោះផង និងជាសាក្សីផង។ ក្រោយពីបានស្ដាប់សក្ខីកម្មក្រុមគណៈវិនិច្ឆ័យបានពិនិត្រឃើញថា  រូបភាពនៃអំពើហិង្សាយេនឌ័រក្រោមរបបខ្មែរក្រហមមានច្រើនដូចជា៖ ការបង្ខំឲ្យរៀបការ ការបង្ខំឲ្យរួមភេទ ការធ្វើឱ្យអាម៉ាស់កេរ្តិ៍ភេទ និងការធ្វើទារុណកម្មផ្លូវភេទ។ រាល់ករណីទាំងអស់នេះ ត្រូវបានប្រព្រឹត្តិដោយជនល្មើសដែលជាអ្នកមានអំណាចក្នុងរបបខ្មែរក្រហម។ កត្តាដែលជំរុញឱ្យមានឧក្រិដ្ឋកម្មទាំងនេះ៖

- ដោយសារអ្នកមានអំណាចរបស់របបខ្មែរក្រហមត្រូវបានផ្ដល់សិទ្ធិអំណាច ក្នុងការចោទប្រកាន់ សម្លាប់ និងធ្វើទារុណកម្មតាមអំពើចិត្ត។ ពួកគេតែងតែដាក់ទារុណកម្មធ្វើឱ្យមានការអាម៉ាស់ផ្នែកផ្លូវភេទជាសាធារណៈ គំរាមកំហែងសម្លាប់ដល់ជនរងគ្រោះមិនឱ្យធ្វើការប្រឆាំងទៅនឹងរបបខ្មែរក្រហម និងប្រកាសនូវរាល់អំពើដែលបានកើតទៅលើពួកគេ។
- ដោយសារអ្នកមានអំណាចរបស់របបខ្មែរក្រហម បានចាត់ទុកការរំលោភបំពានគឺជាការកំសាន្ត។
- ដោយសារអ្នកមានអំណាចរបស់របបខ្មែរក្រហមតែងតែសម្លាប់ជនរងគ្រោះ ដើម្បីបំបាត់ភស្តុតាង បន្ទាប់ពីការរំលោភសេពសន្ថវៈរួច។
- ដោយសារអ្នកមានអំណាចរបស់របបខ្មែរក្រហមមិនត្រូវបានដាក់ទោសទៅតាមនីតិវិធីច្បាប់។

➢ ដោយសារជនរងគ្រោះ ពុំមានសិទ្ធិតវ៉ា ឬមានភាពភ័យខ្លាចរហូតដល់ពុំហ៊ានរាយការណ៍ដល់អជ្ញាធរខ្មែរក្រហម។

*ដោយបានឃើញនូវការឈឺចាប់ និងភាពអយុត្តិធម៌នៅតែបន្ត ដោយគ្មានដំណោះស្រាយណាមួយសមស្របនោះ ក្រុមគណៈវិនិច្ឆ័យសូមធ្វើការថ្លែងនូវអានុសាសន៍ដូចតទៅ៖*

## ការផ្តល់អនុសាសន៍

ក្រោយពីបានស្តាប់នូវសក្ខីកម្មដែលបានបង្ហាញនៅក្នុងកម្មវិធីការស្តាប់សំឡេងស្ត្រីជាមួយមនុស្សជំនាន់ក្រោយ និងដោយបានមើលឃើញនូវបញ្ហាដែលជនរងគ្រោះបានបង្ហាញរួចមក ក្រុមនិស្សិតដែលជា គណៈវិនិច្ឆ័យបានរៀបចំផ្តល់នូវសំណើមួយចំនួនទៅកាន់ភាគីពាក់ព័ន្ធដូចតទៅ៖

ក. ចំពោះរាជរដ្ឋាភិបាលកម្ពុជា

១. ផ្តល់ការស្រលាញ់ដល់ជនរងគ្រោះនិងផ្តល់តម្លៃដល់ជនរងគ្រោះ ដោយបង្កើតឱ្យមានកម្មវិធីលើកទឹកចិត្តដល់ជនរងគ្រោះ ដោយសារអំពើហិង្សាប្រឆាំងយេនឌ័រនៅក្នុងរបបខ្មែរក្រហម និងក្នុងពេលបច្ចុប្បន្ន ដូចជាការផ្តល់សំណងផ្លូវចិត្តតាមរយៈការបង្កើតឱ្យមានគ្លីនិកឬមណ្ឌលផ្តល់ប្រឹក្សា ដោយផ្តល់ជាកញ្ចប់ថវិកា និងមន្ត្រីជំនាញ ដើម្បីផ្តល់ប្រឹក្សាផ្លូវចិត្តដល់ជនរងគ្រោះដោយឥតគិតថ្លៃ។

២. បន្តគាំទ្រ និងសហការជាមួយអង្គការក្រៅរដ្ឋាភិបាល ក្នុងបំណងជំរុញឱ្យមានការផ្តល់ប្រឹក្សាផ្លូវចិត្តឥតគិតថ្លៃ ឱ្យកាន់តែច្រើនដល់ជនរងគ្រោះ។

៣. ដាក់បញ្ចូលបញ្ហាអំពើហិង្សាប្រឆាំងយេនឌ័រ ទាំងនៅក្នុងរបបខ្មែរក្រហមបច្ចុប្បន្ន និងអនាគត ទៅក្នុងកម្មវិធីសិក្សា (អនុវិទ្យាល័យ វិទ្យាល័យ និងមហាវិទ្យាល័យ) ហើយពង្រឹងគុណភាពអប់រំ និងជំរុញការបង្រៀននិងការសិក្សារបស់សិស្សទៅតាមកម្មវិធីសិក្សា ដោយបង្កើតឱ្យមានកម្មវិធីចុះកម្មសិក្សាទៅកន្លែងដែលកើតមានបញ្ហានេះជាក់ស្តែង។

៤. ផ្សព្វផ្សាយពីច្បាប់ទាក់ទងនឹងអំពើហិង្សាប្រឆាំងយេនឌ័រឱ្យបានកាន់តែទូលំទូលាយ ដល់តំបន់ឆ្ងាយៗ នឹងពង្រឹងការអនុវត្តន៍ច្បាប់ហើយដាក់ទណ្ឌកម្មដល់អ្នកប្រព្រឹត្តប្រកបដោយយុត្តិធម៌និងតម្លាភាព ដោយលុបបំបាត់អំពើពុករលួយដើម្បីផ្តល់យុត្តិធម៌ដល់ជនរងគ្រោះ។

៥. បង្កើតឲ្យមានកម្មវិធីប្រកួតប្រជែងលើមុខវិជ្ជាប្រវត្តិសាស្រ្ត ជាពិសេសប្រវត្តិសាស្រ្តខ្មែរក្រហមថ្នាក់ជាតិ ដើម្បីជំរុញលើកទឹកចិត្តដល់យុវជនជំនាន់ក្រោយ (ប្រជាជន) ឱ្យស្រាវជ្រាវពី

ប្រវត្តិសាស្ត្រឱ្យកាន់តែច្បាស់។

៦. អភិរក្សតំបន់ឧក្រិដ្ឋកម្មនានាដែលនៅសល់ពីរបបខ្មែរក្រហម ដើម្បីទុកជាភស្តុតាងដើម្បីបង្ហាញដល់ក្មេងជំនាន់ក្រោយ ព្រោះថាភស្តុតាងទាំងនេះកំពុងនឹងបានបាត់បង់។

៧. គួរបោះកញ្ចប់ថវិការមួយដែលមានលក្ខណៈឯករាជ្យ ទៅឱ្យអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការទៅលើបញ្ហាអំពើហិង្សាប្រឆាំងយេនឌ័រនៅក្នុងរបបខ្មែរក្រហម ដើម្បីបន្តសកម្មភាពឱ្យបានច្រើនបន្ថែមទៀត

៨. ពង្រឹងនូវយន្តការការពារនិងធានាទៅលើសន្តិសុខប្រទេស ថានឹងមិនឲ្យមាននូវបញ្ហានេះកើតឡើងម្ដងទៀត។

៩. ជំរុញឱ្យមានការបង្កើតក្លឹបដែលធ្វើការផ្ដោតទៅលើបញ្ហាយេនឌ័រនៅតាមសាកលវិទ្យាល័យ។

ខ. អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (សាលាក្ដីខ្មែរក្រហម)

១. ដាក់បញ្ចូលឧក្រិដ្ឋកម្មទាក់ទងនឹងអំពើហិង្សាយេនឌ័រផ្សេងទៀត ក្រៅពីករណីការបង្ខំឲ្យរៀបការក្នុងរបបខ្មែរក្រហមទៅក្នុងសំណុំរឿង ០០៣ ឬ០០៤ បន្តទៀត ដើម្បីស្វែងរកយុត្តិធម៌និងសន្តិភាពផ្លូវចិត្តដល់ជនរងគ្រោះដោយកាត់ទោសផ្ទាល់លើជនល្មើស។

២. ពន្លឿនការកាត់ទោស ជាពិសេសសំណូមពរឱ្យមានការកាត់ទោសក្នុងករណីការបង្ខំរៀបការក្នុងករណី ០០២/២ ដែលជាសំណុំរឿងបន្ទាប់។

គ. អង្គការមិនមែនរដ្ឋាភិបាល

១. ពង្រីកសកម្មភាពគម្រោងទាក់ទងនឹងអំពើហិង្សាប្រឆាំងយេនឌ័រក្នុងរបបខ្មែរក្រហម ដើម្បីឲ្យជនរងគ្រោះជាច្រើនទៀត មានឱកាសចែករំលែករឿងរ៉ាវរបស់ពួកគាត់មកកាន់អ្នកជំនាន់ក្រោយបានដឹងអំពីរឿងនេះឲ្យតែកាន់តែទូលំទូលាយ។

២. បង្កើននូវសកម្មភាពដូចជាវគ្គសិក្ខាសិលាវេទិកាសាធារណៈ ឬវគ្គបណ្ដុះបណ្ដាលដល់យុវជនអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ការផ្សះផ្សាផ្លូវចិត្ត អំពីហិង្សាប្រឆាំងយេនឌ័ររួមទាំងការចុះកម្មសិក្សាទៅតាមតំបន់ឧក្រិដ្ឋកម្មនានាដោយផ្ទាល់។

៣. បង្កើននូវការផ្តល់ការប្រឹក្សាផ្លូវចិត្តពីអ្នកជំនាញដល់ជនរងគ្រោះឲ្យកាន់តែច្រើន។

៤. តាមដាននូវការអនុវត្តច្បាប់អំពើហិង្សាប្រឆាំងយេនឌ័ររបស់អាជ្ញាធរ និងប្រជាពលរដ្ឋ ព្រមទាំងផ្តល់អនុសាសន៍សំរាប់ការអនុវត្តច្បាប់ឲ្យបានត្រឹមត្រូវ។

៥. ចូលរួមសកម្មភាពជាមួយរដ្ឋាភិបាលនៃប្រទេស ដែលធ្លាប់ជួបប្រទះនឹងរឿងអំពើហិង្សាប្រឆាំងយេនឌ័រ ដើម្បីធ្វើការផ្លាស់ប្តូរនូវបទពិសោធន៍និងរកដំណោះស្រាយឲ្យកាន់តែមានភាពល្អប្រសើរនិងមានប្រសិទ្ធភាព។

៦. បង្កើតការគាំទ្រនិងចូលរួមក្នុងសកម្មភាពផ្សេងៗ ដើម្បីទប់ស្កាត់និងប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាប្រឆាំងនឹងយេនឌ័រ។

ឃ. យុវជន

១. ធ្វើការសិក្សាស្រាវជ្រាវពីប្រវត្តិសាស្ត្ររបស់ខ្លួនឲ្យបានស៊ីជម្រៅ ជាពិសេសគឺការសិក្សាពីអាថ៌កំបាំងនៃអំពើហិង្សាប្រឆាំងយេនឌ័រក្នុងរបបខ្មែរក្រហម ហើយប្រើប្រាស់ចំណេះដឹងទាំងនោះឲ្យបានត្រឹមត្រូវ ក្នុងបំណងទប់ស្កាត់កុំឲ្យជាន់ដានប្រវត្តិសាស្ត្រចាប់ពីបច្ចុប្បន្ននិងទៅអនាគត។

២. ចូលរួមរាល់សកម្មភាពផ្សេងៗដែលទាក់ទងទៅនឹងការអប់រំ អំពីអំពើហិង្សាប្រឆាំងយេនឌ័រ ដូចជាវគ្គបណ្តុះបណ្តាលវេទិកាសាធារណៈសិក្ខាសាលា និងការធ្វើទស្សនៈកិច្ចសិក្សាជាដើម ដើម្បីឲ្យមានចំណេះដឹងពីបញ្ហានេះហើយជៀសវាងនូវការប្រព្រឹត្តនូវអំពើទាំងនោះ។

៣. ធ្វើការចែករំលែកព័ត៌មាន ចំណេះដឹងទៅកាន់អ្នកដទៃ ដើម្បីលុបបំបាត់រាល់ទម្រង់នៃអំពើហិង្សាប្រឆាំងយេនឌ័រនៅកម្ពុជា និងការលុបបំបាត់ការរើសអើងលើជនរងគ្រោះហើយងាកមកលើកទឹកចិត្តដល់ជនរងគ្រោះ តាមរយៈការផ្តល់ការគាំទ្រដល់ពួកគាត់។

៤. ធ្វើការប្តេជ្ញាថា នឹងមិនប្រព្រឹត្តជាដាច់ខាត នូវគ្រប់ទម្រង់ទាំងអស់នៃអំពើហិង្សាប្រឆាំងយេនឌ័រ ព្រមទាំងជំរុញឱ្យមនុស្សនៅជុំវិញខ្លួនជាពិសេសក្រុមគ្រួសារ និងមិត្តភ័ក្តិ រួមគ្នាបញ្ឈប់អំពើហិង្សាប្រឆាំងយេនឌ័រ។ រាយការណ៍ទៅអាជ្ញាធរមានសមត្ថកិច្ចឲ្យទាន់ពេលវេលានៅពេលមានអំពើហិង្សា ប្រឆាំងយេនឌ័រកើតឡើង។

ង. ម្ចាស់ជំនួយ

១. ផ្តល់នូវថវិកាដល់អង្គការមិនមែនរដ្ឋាភិបាល ឬយុវជនដែលមានគម្រោងធ្វើការទាក់ទងនឹងអំពើហិង្សាប្រឆាំងយេនឌ័រក្នុងរបបខ្មែរក្រហម។

២. បន្តនូវការគាំទ្រជាថវិកា និងជាសម្ភារៈ ចំពោះអង្គការមិនមែនរដ្ឋាភិបាលនិងយុវជនឱ្យបន្តការអនុវត្តនិងបង្កើនសកម្មភាពគម្រោង ដែលទាក់ទងទៅនឹងអំពើហិង្សាប្រឆាំងយេនឌ័រ ដើម្បីធ្វើសកម្មភាពជួយដល់ជនរងគ្រោះ។

៣. ផ្តល់ជំនួយដល់ការចងក្រងឯកសារប្រវត្តិសាស្ត្រ ទាក់ទងទៅនឹងរបបខ្មែរក្រហម ដែលត្រួតពិនិត្យដោយអ្នកជំនាញ ដើម្បីទុកជាឯកសារដល់កូនចៅជំនាន់ក្រោយទៀតឲ្យបានដឹងពីរឿងពិតពីអតីតកាលរបស់អ្នកជំនាន់មុន។

៤. ជួយដល់អង្គការមិនមែនរដ្ឋាភិបាលបន្តឱ្យមានការប្រារព្ធកម្មវិធី ការស្តាប់សំឡេងស្ត្រីនៅឆ្នាំក្រោយៗទៀត។

៥. បន្តធ្វើការផ្សព្វផ្សាយជាអន្តរជាតិនូវកម្មវិធី ការស្តាប់សំឡេងស្ត្រី ដើម្បីឱ្យប្រទេសដែលធ្លាប់ជួបប្រទះនូវបញ្ហាស្រដៀងគ្នាជាមួយប្រទេសកម្ពុជាយកទៅធ្វើជាគំរូ។

ច. ប្រព័ន្ធផ្សព្វផ្សាយ

១. ជំរុញការផ្សព្វផ្សាយនូវព័ត៌មានដែលទាក់ទងនឹងអំពើហិង្សាប្រឆាំងយេនឌ័រ ឲ្យបានទូលំទូលាយដើម្បីឲ្យប្រជាជនទូទៅបានដឹងពីបញ្ហានេះឲ្យកាន់តែស៊ីជម្រៅ។

# សេចក្តីថ្លែងអំណរគុណ




ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា អង្គការចិត្តសង្គមអន្តរវប្បធម៌ និងអង្គភាពគាំពារជនរងគ្រោះ សូមសម្តែងសេចក្តីថ្លែងអំណរគុណយ៉ាងក្រៃលែងចំពោះអ្នកគ្រប់រូប និងអង្គការដែលបានចូលរួមបង្កើតវេទិកាការស្តាប់សំឡេងស្ត្រីជាមួយមនុស្សជំនាន់ក្រោយឆ្នាំ២០១៣ឱ្យទទួលបានជោគជ័យ។

ជាបឋម យើងសូមថ្លែងអំណរគុណចំពោះអ្នកផ្តល់សក្ខីកម្ម រួមមាន អ្នកស្រី មុំ វន់  ឡោះ វណ្ណា យ៉ាំ ឡាស និង ជា ណុំ ដែលមានសេចក្តីក្លាហាន កម្លាំងចិត្ត និងការជំរុញចិត្តក្នុងការចូលរួមវេទិកានេះ។

យើងសូមថ្លែងអំណរគុណចំពោះ ក្រុមការងារពិសេសនៃនិស្សិត និងនិស្សិតដែលបានដើរតួនាទីជាគណៈវិនិច្ឆ័យ ដើម្បីជាគំរូដល់មនុស្សជំនាន់ក្រោយ៖

*ឆេង ចាន់នីតា / ឈុន សៀកវ៉ា អ៊ិន រដ្ឋា / កែវ បុប្ផាឧសភា / កែវ រតនា / ខុន ចន្ថា / យុត អ៊ិច / Adi-Mere Misivono / ណៃ ឧត្តម / ណុច ស្រីនាង / ផៃ សភាបញ្ញា / រីម សុវណ្ណារី / សែម ហាក់ / ស ជីវហ្គិច / ថន ភារ៉ូ / និង / យូន ស្រីនិច។*

យើងក៏សូមអរគុណដល់វាគ្មិន រួមមាន លោក សុខ សំអឿន ដួង សាវន និង ហង្ស វណ្ណៈ អ្នកសម្របសម្រួល ថើរេសា ឌី ឡាងជីស និង យូ សុធារី អ្នកផ្តល់ប្រឹក្សាដល់គណៈវិនិច្ឆ័យ កាស៊ូមី ណាកាហ្គាវ៉ា និងអ្នកប្រតិចារិកជាតិ និងអន្តរជាតិ ដែលចូលរួមចំណែកក្នុងវេទិកានេះ។

យើងសូមអរគុណដល់ផ្នែកប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងទំនាក់ទំនងនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញសម្រាប់ការថតអំពីវេទិកាជាឯកសារភាពយន្ត។

យើងសូមថ្លែងអំណរគុណយ៉ាងក្រៃលែងចំពោះមូលនិធិសប្បុរសរបស់អង្គការសហប្រជាជាតិដើម្បីបញ្ឈប់ហិង្សាលើស្ត្រី និងការគាំទ្របច្ចេកទេសដែលផ្តល់ដោយសេវាសន្តិភាពស៊ីវិលអង្គការ GIZ។

# អ្នករៀបចំ



### ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា / Cambodian Defenders Project (CDP)

ក្នុងនាមជាអង្គការសង្គមស៊ីវិលដែលមានវ័យចំណាស់ជាងគេក្នុងប្រទេសកម្ពុជា ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជាប្តេជ្ញាចិត្តផ្តល់អ្នកតំណាងផ្នែកច្បាប់ដោយឥតគិតថ្លៃដល់ប្រជាជនក្រីក្រ និងជនងាយរងគ្រោះ ក៏ដូចជា លើកកម្ពស់នីតិរដ្ឋ ការបង្កើតប្រព័ន្ធតុលាការ និងអភិបាលកិច្ចបែបប្រជាធិបតេយ្យក្នុងប្រទេសកម្ពុជា។ សិទ្ធិមនុស្សរបស់ស្ត្រី ជាពិសេសលទ្ធភាពទទួលបានយុត្តិធម៌ តែងតែងជាការងារចម្បងរបស់ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា។ ក្នុងឆ្នាំ២០០៦ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជាបានធ្វើការសិក្សាស្រាវជ្រាវមួយក្នុងចំណោមការសិក្សាស្រាវជ្រាវដំបូងដទៃទៀត ដែលផ្តោតលើអំពើហិង្សាយេនឌ័រក្នុងរបបខ្មែរក្រហម។ ក្នុងឆ្នាំ២០០៩ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជាបានបង្កើតគម្រោង ដើម្បីលើកកម្ពស់ការយល់ដឹងអំពីការកើតឡើងនូវអំពើហិង្សាក្នុងរបបខ្មែរក្រហម និងដើម្បីបង្កើនលទ្ធភាពឱ្យអ្នកនៅរស់រានមានជីវិតពីរបបនេះទទួលបានយុត្តិធម៌ និងការគាំទ្រ។

### អង្គការចិត្តសង្គមអន្តរវប្បធម៌កម្ពុជា / Transcultural Psychosocial Organization Cambodia (TPO)

អង្គការចិត្តសង្គមអន្តរវប្បធម៌កម្ពុជា ត្រូវបានបង្កើតឡើងក្នុងប្រទេសកម្ពុជាក្នុងខែកុម្ភៈ ឆ្នាំ១៩៩៥ ជាអង្គការសាខារបស់អង្គការចិត្តសង្គមអន្តរវប្បធម៌អន្តរជាតិនៃប្រទេសហូឡង់។ បន្ទាប់ពីបានចុះឈ្មោះក្នុងបញ្ជីក្នុងឆ្នាំ២០០០ ក្នុងនាមជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកឯករាជ្យ អង្គការចិត្តសង្គមអន្តរវប្បធម៌កម្ពុជា គឺជាអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាឈានមុខគេ ក្នុងវិស័យសុខភាពផ្លូវចិត្ត និងអន្តរាគមន៍ ចិត្តសង្គម។ បន្ទាប់ពី អ.វ.ត.ក ត្រូវបានបង្កើតឡើងអង្គការចិត្តសង្គមអន្តរវប្បធម៌បានផ្តួចផ្តើមនូវកម្មវិធីចិត្តសង្គមគ្រប់ជ្រុងជ្រោយមួយ ដើម្បីផ្តល់ការគាំទ្រដល់សាក្សី និងភាគីដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចជា លើកកម្ពស់ការយល់ដឹងអំពីបញ្ហាសុខភាពផ្លូវចិត្ត ដែលកើតមានក្នុងចំណោមប្រជាជនទូទៅ។ ការសហការយ៉ាងជិតស្និទ្ធជាមួយសាក្សី និងអង្គភាពគាំពារសាក្សី និងអ្នកជំនាញនៅ អ.វ.ត.ក និងអង្គភាពគាំពារជនរងគ្រោះ អង្គការចិត្តសង្គមអន្តរវប្បធម៌ផ្តល់សេវាចិត្តសង្គមជាច្រើនតាមរយៈអ្នកជំនាញសុខភាពផ្លូវចិត្តដែលជាជនជាតិខ្មែរ។ ការផ្តល់សេវាទាំងនេះ មានចាប់ពីការផ្តល់ការគាំទ្រផ្នែកចិត្តសាស្ត្រនៅនឹងកន្លែង និងបន្ទាប់ពីដំណើរការនីតិវិធីរបស់ អ.វ.ត.ក រហូតដល់ការអនុវត្តជាសាមញ្ញនូវការព្យាបាលការប៉ះទង្គិចផ្លូវចិត្ត និងក្រុមជួយខ្លួនឯងតាមសហគមន៍។

## អង្គភាពគាំពារជនរងគ្រោះរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា / Victims Support Section of the Extraordinary Chamber of the Courts of Cambodia (VSS)

អង្គភាពគាំពារជនរងគ្រោះបានបង្កើត ដើម្បីគាំទ្រដល់ អ.វ.ត.ក តាមរយៈការផ្តល់ជំនួយដល់ជនរងគ្រោះ ដែលមានបំណងចូលរួមក្នុងដំណើរការ។ ដំណើរការនេះរួមមានដំណើរការនៃការរៀបចំពាក្យបណ្តឹង និងពាក្យស្នើសុំរបស់ជនរងគ្រោះ ដែលស្វែងរកការអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការចូលរួមក្នុងដំណើរការ។ ដើម្បីជួយដល់ជនរងគ្រោះ អង្គភាពគាំពារជនរងគ្រោះផ្តល់ការគាំទ្រផ្លូវច្បាប់ និងរដ្ឋបាលដល់មេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណី និងផ្តល់ព័ត៌មានដល់ជនរងគ្រោះអំពីសិទ្ធិរបស់ពួកគេទាក់ទងនឹងការចូលរួម និងសំណង។ អង្គភាពនេះគាំទ្រដល់ការងាររបស់សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត តាមរយៈការជួយដល់ដំណើរការរៀបចំពាក្យបណ្តឹង និងពាក្យស្នើសុំធ្វើជាភាគីដើមបណ្តឹងរដ្ឋប្បវេណី និងការរៀបចំរបាយការណ៍សម្រាប់ការិយាល័យទាំងនេះ។ អង្គភាពនេះក៏ធ្វើការទាក់ទងជាមួយភាគីដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីដឹងអំពីស្ថានភាពនៃពាក្យបណ្តឹង និងពាក្យស្នើសុំរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី និងផ្តល់បច្ចុប្បន្នភាពព័ត៌មានអំពីភាពរីកចម្រើននៃករណីបណ្តឹងនីមួយៗដល់ភាគីដើមបណ្តឹងរដ្ឋប្បវេណី។ ជាចុងក្រោយ អង្គភាពគាំពារជនរងគ្រោះ ធានាដល់សុវត្ថិភាព និងសុខុមាលភាពរបស់ជនរងគ្រោះ ដែលចូលរួមក្នុងដំណើរការនេះ។ ការធានានេះរួមមាន ការធានាថា ជនរងគ្រោះទទួលបានការយល់ដឹងសមស្របអំពីគ្រោះថ្នាក់ដែលអាចកើតមាននៅពេលខ្លះក្នុងការចូលរួមដំណើការនេះ ក៏ដូចជាការផ្តល់វិធានការការពារ និងជំនួយផ្សេងទៀត ដូចជាការគាំទ្រចិត្តសង្គមដល់ជនរងគ្រោះ។

# ឧបសម្ព័ន្ធ



## ឧបសម្ព័ន្ធ ក ៖ របៀបវារៈនៃការស្តាប់សំឡេងស្ត្រីជាមួយមនុស្សជំនាន់ក្រោយការស្តាប់សំឡេងស្ត្រីជាមួយមនុស្សជំនាន់ក្រោយ ដែលរៀបចំឡើងនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ រាជធានីភ្នំពេញ

### របៀបវារៈ

| | |
|---|---|
| 7:30 – 8:00 | ការចុះឈ្មោះ |
| 8:00 | គោរពភ្លេងជាតិ |
| 8:00 – 8:15 | សុន្ទរកថាស្វាគមន៍<br>*សុខ សំអឿន នាយកប្រតិបត្តិ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា* |
| 8:15 – 8:30 | សេចក្តីសង្ខេបអំពីផ្លូវចិត្ត |
| | *ស្រៀ រដ្ឋា អ្នកចិត្តវិទ្យា ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា* |
| 8:30 – 9:00 | សក្ខីកម្មរបស់អ្នកជំនាញ ៖ អំពើហិង្សាយេនឌ័រក្នុងរបបខ្មែរក្រហម<br>*ដួង សាវ៉ន អ្នកសម្របសម្រួលគម្រោង ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា* |
| 9:00 – 10:00 | សក្ខីកម្មរបស់អ្នកនៅរស់រានមានជីវិត លោកស្រី មុំ វន់ |
| 10:00 – 10:30 | សម្រាក |
| 10:30 – 11:30 | សក្ខីកម្មរបស់អ្នកនៅរស់រានមានជីវិត លោកស្រី យ៉ាំ ឡាស់ |
| 11:30 – 12:30 | សក្ខីកម្មរបស់អ្នកនៅរស់រានមានជីវិត លោកស្រី ឡោះ វណ្ណា |
| 12:30 – 14:00 | អាហារថ្ងៃត្រង់ |
| 14:00 – 15:00 | សក្ខីកម្មរបស់អ្នកនៅរស់រានមានជីវិត លោកស្រី ជា ណុំ |
| 15:00 – 16:00 | វគ្គចោទសំណួរ |
| *16:00 – 16:30* | សម្រាក |
| 16:30 – 17:00 | សេចក្តីថ្លែងការណ៍របស់គណៈវិនិច្ឆ័យ |
| 17:00 – 17:30 | បិទកម្មវិធី<br>*ហង្ស វណ្ណៈ ប្រធានអង្គភាពគាំពារជនរងគ្រោះ* |

## ឧបសម្ព័ន្ធ ខ ៖ សេចក្តីប្រកាសព័ត៌មានអំពីការស្ដាប់សំឡេងស្ត្រីជាមួយមនុស្សជំនាន់ក្រោយ

### ការប្រកាសព័ត៌មាន

សម្រាប់ការប្រកាសព័ត៌មានបន្ទាន់ ៖ ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៣

### ការស្ដាប់សំឡេងស្ត្រីជាមួយមនុស្សជំនាន់ក្រោយឆ្នាំ២០១៣

ដោយមានភាពជាដៃគូជាមួយអង្គការចិត្តសង្គមអន្តរវប្បធម៌ និងអង្គភាពគាំពារជនរងគ្រោះនៅអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា បានរៀបចំវេទិកាលើកទីបីនៃការស្ដាប់សំឡេងស្ត្រីជាមួយមនុស្សជំនាន់ក្រោយនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣។

វេទិកាការស្ដាប់សំឡេងស្ត្រីជាមួយមនុស្សជំនាន់ក្រោយ បានបង្ហាញពីការផ្តល់សក្ខីកម្មជាសាធារណៈរបស់ស្ត្រីបួននាក់ ដែលមានភាពក្លាហានក្នុងការនិយាយរៀបរាប់អំពីអំពើហិង្សាយេនឌ័រក្នុងរបបខ្មែរក្រហម។ រឿងរ៉ាវទាក់ទងនឹងការរៀបការដោយបង្ខំ ការរំលោភសេពសន្ថវៈ ការបង្ករបួស និងទណ្ឌកម្មផ្លូវភេទ គឺសុទ្ធសឹងជាអំពើធ្វើឱ្យមានភាពឈឺចាប់ផ្លូវចិត្ត។ ការរស់រាននៅមានជីវិតរបស់ស្ត្រីទាំងនេះគឺជាភស្តុតាងនៃភាពអត់ធ្មត់ និងការប្តេជ្ញាចិត្តរបស់ពួកគេ។

គោលបំណងនៃវេទិកាការស្ដាប់សំឡេងស្ត្រីជាមួយមនុស្សជំនាន់ក្រោយក្នុងឆ្នាំនេះ គឺដើម្បីលើកកម្ពស់ចំណេះដឹង និងការយល់ដឹងរបស់មនុស្សជំនាន់ក្រោយអំពីប្រវត្តិសាស្ត្រនៃខ្មែរក្រហម ដោយដឹងអំពីបទពិសោធន៍របស់អ្នកនៅរស់រានមានជីវិតដែលទទួលរងអំពើហិង្សាផ្លូវភេទ។ វេទិកានេះមានគោលដៅឱ្យមានការចូលរួមពីយុវជនក្នុងការតស៊ូមតិ ដើម្បីផ្តល់ការគាំទ្រ និងយុត្តិធម៌ដល់អ្នកនៅរស់រានមានជីវិត ក៏ដូចជា ការការពារអំពើហិង្សាយេនឌ័រក្នុងពេលបច្ចុប្បន្ន និងអនាគត។ ភាគច្រើននៃអ្នកចូលរួមច្រើនជាង៤០០នាក់ គឺជាសិស្សសាកលវិទ្យាល័យ រួមទាំង សមាជិកគណៈវិនិច្ឆ័យទាំងប្រាំមួយនាក់ផងដែរ(ជាមួយតំណាងមកពីវិស័យច្បាប់ ហិរញ្ញវត្ថុ ចិត្តសាស្ត្រ និងយេនឌ័រ)។

### ចំណុចសំខាន់ៗ និងអនុសាសន៍នៃសេចក្តីថ្លែងការណ៍របស់គណៈវិនិច្ឆ័យ

សម្រាប់សិស្សជាច្រើនដែលជាសមាជិកគណៈវិនិច្ឆ័យ និងជាអ្នកចូលរួមស្ដាប់ នេះគឺជាលើកដំបូងដែលយើងបានស្ដាប់អំពីអំពើហិង្សាយេនឌ័រដែលកើតមានក្នុងរបបខ្មែរក្រហម។ យើងទទួលបានព័ត៌មានជាច្រើនពីអ្នកផ្តល់សក្ខីកម្ម ហើយយើងមានការចាប់អារម្មណ៍ និងការជំរុញទឹកចិត្តដោយបានឃើញសេចក្តីក្លាហាន និងភាពរឹងមាំឡើងវិញរបស់ជនរងគ្រោះ។ យើងផ្តល់ជាអនុសាសន៍ដូចខាងក្រោម។

រដ្ឋាភិបាលត្រូវ ៖

- បង្កើតសំណងសម្រាប់ការប្រឹក្សា និងការគាំទ្រដទៃទៀតផ្តល់ជូនដោយឥតគិតថ្លៃដល់អ្នកនៅរស់រានមានជីវិត ដែលទទួលរងអំពើហិង្សាយេនឌ័រក្នុងរបបខ្មែរក្រហម
- អនុវត្តច្បាប់ និងធានាឱ្យមានការដាក់ទណ្ឌកម្មលើជនល្មើសដែលប្រព្រឹត្តអំពើហិង្សាយេនឌ័រក្នុងរបបខ្មែរក្រហម និងផ្តល់តម្លាភាពឱ្យបានកាន់តែប្រសើរក្នុងដំណើរការច្បាប់
- ធានាការពារភស្តុតាងប្រវត្តិសាស្ត្រនៃអំពើហិង្សានេះ សម្រាប់មនុស្សជំនាន់ក្រោយឱ្យបានយល់ដឹង ដោយការថែរក្សាទីតាំងនៃបទឧក្រិដ្ឋ និងភស្តុតាងនៃការធ្វើទារុណកម្ម និងបង្កើតឱ្យមានការប្រកួតប្រជែងជាប្រវត្តិសាស្ត្រស្តីពីប្រធានបទនេះនៅថ្នាក់ជាតិ ដើម្បីឱ្យមានការចូលរួមពីយុវជន។
- លើកកម្ពស់ការយល់ដឹងថ្នាក់ជាតិអំពីអំពើហិង្សាយេនឌ័រក្នុងរបបខ្មែរក្រហម ដោយបញ្ចូលព័ត៌មានអំពីបញ្ហានេះទៅក្នុងកម្មវិធីសិក្សានៅសាលារៀន និងមហាវិទ្យាល័យ និងអនុវត្តទស្សនកិច្ចសិក្សានៅទីតាំងនៃបទឧក្រិដ្ឋ
- ផ្តល់មូលនិធិដល់អង្គការមិនមែនរដ្ឋាភិបាលក្នុងការបំពេញការងារលើបញ្ហាអំពើហិង្សាយេនឌ័រក្នុងរបបខ្មែរក្រហម
- បង្កើតយន្តការដែលធានាថា របបខ្មែរក្រហមបែបនេះនឹងមិនកើតឡើងម្តងទៀតឡើយ។

អ.វ.ត.ក ត្រូវ ៖

- បង្កើនល្បឿនក្នុងការបញ្ចប់សំណុំរឿង០០២
- បញ្ចូលបទឧក្រិដ្ឋអំពើហិង្សាយេនឌ័រស្តីពីការរៀបការដោយបង្ខំទៅក្នុងដីការចោទប្រកាន់សំណុំរឿង០០៣ និង០០៤។

អង្គការមិនមែនរដ្ឋាភិបាលត្រូវ ៖

- បំពេញការងារស្តីពីអំពើហិង្សាផ្លូវភេទក្នុងរបបខ្មែរក្រហម ដូច្នេះ បញ្ហានេះមិនត្រូវបានបំភ្លេចចោល
- ផ្តល់ការប្រឹក្សា និងការគាំទ្រផ្សេងៗដល់អ្នកនៅរស់រានមានជីវិត និងផ្តល់ឱកាសដល់ពួកគេប្រាប់អំពីរឿងរ៉ាវរបស់ខ្លួន និងផ្តល់ការគាំទ្រពួកគេ
- សហការបន្ថែមជាមួយអាជ្ញាធរ និងអនុវត្តច្បាប់ដែលឆ្លើយតបនឹងអំពើហិង្សាយេនឌ័រ
- រៀបចំសិក្ខាសាលា វេទិកា និងការបណ្តុះបណ្តាល ដើម្បីឱ្យយុវជនជំនាន់ក្រោយចូលរួមយល់ដឹងអំពីបញ្ហាអំពើហិង្សាយេនឌ័រក្នុងរបបខ្មែរក្រហម និងចូលរួមបង្ការកុំឲ្យមានអំពើហិង្សាបែបនេះ និងធ្វើការផ្សះផ្សារ

- សហការជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងប្រទេសដទៃទៀត ដែលមានបទពិសោធន៍ទាក់ទងនឹងសង្គ្រាម ដើម្បីចែករំលែកបទពិសោធន៍ និងចំណេះដឹងអំពីការឆ្លើយតបនឹងបញ្ហាទាំងនេះ
- ធ្វើការសិក្សាស្រាវជ្រាវស៊ីជម្រៅអំពីប្រវត្តិនៃអំពើហិង្សាយេនឌ័រក្នុងរបបខ្មែរក្រហម ដើម្បីឱ្យមានការយល់ដឹងកាន់តែប្រសើរអំពីអតីតកាល និងប្រាប់ព័ត៌មានអំពីការឆ្លើយតបនឹងការការពារ។

យុវជនត្រូវ ៖

- គាំទ្រជនរងគ្រោះនៃអំពើហិង្សាយេនឌ័រក្នុងពេលកន្លងមក និងពេលបច្ចុប្បន្ន
- រាយការណ៍ឱ្យបានសកម្មអំពីអំពើហិង្សាយេនឌ័រទៅកាន់អាជ្ញាធរ
- ចូលរួមក្នុងការបណ្ដុះបណ្ដាល និងការសិក្សាស្រាវជ្រាវអំពីអំពើហិង្សាយេនឌ័រដែលកើតមានក្នុងពេលកន្លងមក និងបច្ចុប្បន្ន ដើម្បីការយល់ដឹង និងការពារអំពើហិង្សាកុំឲ្យកើតឡើង
- ចែករំលែកព័ត៌មានជាមួយគ្នាទៅវិញទៅមក។

អ្នកផ្ដល់ជំនួយត្រូវ ៖

- ផ្ដល់មូលនិធិបន្ថែមដល់អង្គការមិនមែនរដ្ឋាភិបាលក្នុងការបំពេញការងារទាក់ទងនឹងអំពើហិង្សាយេនឌ័រ
- គាំទ្រការចងក្រងឯកសារអំពីអំពើហិង្សាយេនឌ័រកើតមានក្នុងពេលជម្លោះ ដើម្បីឱ្យមនុស្សជំនាន់ក្រោយយល់ដឹងអំពីបញ្ហាទាំងនេះ
- គាំទ្រអង្គការមិនមែនរដ្ឋាភិបាលក្នុងការរៀបចំការស្ដាប់សំឡេងស្ត្រីជាមួយមនុស្សជំនាន់ក្រោយនាពេលអនាគត
- លើកកម្ពស់ការយល់ដឹងអំពីប្រធានបទនេះក្នុងកម្រិតអន្តរជាតិ និងចែករំលែកបទពិសោធន៍ជាមួយអ្នកដទៃ។

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានត្រូវ ៖

- ត្រូវផ្សព្វផ្សាយអំពីប្រធានបទនេះឱ្យកាន់តែទូលំទូលាយ ដើម្បីធានាថា សាធារណៈជន និងអាជ្ញាធរបានដឹងអំពីអំពើហិង្សានេះ ហើយអ្នកនៅរស់រានមានជីវិតបានបញ្ចេញសំឡេងរបស់ខ្លួន។

## *ជំហានបន្ទាប់*

ក្នុងសប្ដាហ៍បន្ទាប់ គណៈវិនិច្ឆ័យនឹងដាក់ចេញនូវសេចក្ដីថ្លែងការណ៍ផ្លូវការពេញលេញ។ ក្នុងរយៈពេលប៉ុន្មានខែខាងមុខ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជានឹងរៀបចំការផ្ដល់សក្ខីកម្ម និងសេចក្ដី

ថ្លែងការណ៍របស់គណៈវិនិច្ឆ័យ និងដាក់ឯកសារទាំងនេះជារបាយការណ៍ដែលអាចរកបានជាសាធារណៈ ដែលនឹងត្រូវបានផ្សព្វផ្សាយអំពីអំពើហិង្សាយេនឌ័រក្នុងគេហទំព័រ www.gbvkr.org

ខ្សែភាពយន្តឯកសារស្តីពីការស្តាប់សំឡេងស្ត្រីជាមួយមនុស្សជំនាន់ក្រោយក្នុងឆ្នាំនេះ ក៏នឹងត្រូវបង្ហោះក្នុងគេហទំព័រនេះផងដែរ។ សូមចូលទៅកាន់គេហទំព័រនេះសម្រាប់ភាពយន្តឯកសារនេះ និងរបាយការណ៍នៃការស្តាប់សំឡេងស្ត្រីជាមួយមនុស្សជំនាន់ក្រោយដែលរៀបចំក្នុងឆ្នាំ២០១១ និង ២០១២។

## *អ្នកចូលរួមក្នុងការស្តាប់សំឡេងស្ត្រីជាមួយមនុស្សជំនាន់ក្រោយ*

អ្នកផ្តល់សក្ខីកម្មដែលជាអ្នកនៅរស់រានមានជីវិត៖ លោកស្រី មុំ វន់ យ៉ាំ ឡាស់ ឡោះ វណ្ណា និងជា ណុំ។

គណៈវិនិច្ឆ័យ (PUC, RULE, RUPP ចិត្តវិទ្យា ច្បាប់ ហិរញ្ញវត្ថុ និងយេនឌ័រ)

គណៈវិនិច្ឆ័យសំខាន់ៗ ៖ ស ជីវហ្គេច ផៃ សុភាបញ្ញា យុត អ៊ិច រឹម សុវណ្ណារី អ៊ុន រដ្ឋា កែវ បុប្ផាឧសភា

គណៈវិនិច្ឆ័យគាំទ្រ ៖ Adi Mere MISIVONO ខុន ចន្ថា ឆេង ច័ន្ទនីតា ឈុន ស៊ីក្វា កែវ រតនៈ នៃ ឧត្តម នុច ស្រីនាង សែម ហាក់ ថន ភាជ យួន ស្រីនិច

ក្រុមរៀបចំរបស់ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ៖ លោក ដួង សាវន កញ្ញា ហង្ស ចរិយា កញ្ញា ស្រៀ រដ្ឋា កញ្ញា យី ប៊ីនី។